# សំណួរ-ចម្លើយ ៥៥

## ជំនួយស្មារតី

## ចំណេះដឹងវិជ្ជាពលរដ្ឋ

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧




- អ្វីគឺជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌?
- តើត្រូវមានវិធានការពិសេសអ្វីខ្លះ ដើម្បីបង្កើនចំនួនស្ត្រីជាតំណាងជាប់ឆ្នោត?
- តើយុវជនគួរធ្វើយ៉ាងណាដើម្បីឲ្យមានការគិតគូរខ្ពស់ពីអ្នកដឹកនាំ និងមានតម្លៃក្នុងសង្គម?
- មុននឹងសម្រេចចិត្តបោះឆ្នោត តើលោកអ្នកត្រូវពិនិត្យមើលអ្វីខ្លះ?

ខែឧសភា ឆ្នាំ២០១៧

# ៥៩ សំណួរ_ ចម្លើយ

# ជំនួយស្មារតីចំណេះដឹងវិជ្ជាពលរដ្ឋ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧

- *អ្វីគឺជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌?*
- *តើត្រូវមានវិធានការណ៍ពិសេសអ្វីខ្លះ ដើម្បីបង្កើនចំនួនស្ត្រីជាតំណាងជាប់ឆ្នោត?*
- *តើយុវជនគួរធ្វើយ៉ាងណាដើម្បីឲ្យមានការគិតគូរខ្ពស់ពីអ្នកដឹកនាំ និងមានតម្លៃក្នុងសង្គម?*
- *មុននឹងសម្រេចចិត្តបោះឆ្នោត តើលោកអ្នកត្រូវពិនិត្យមើលអ្វីខ្លះ ?*

# មាតិកា


**លេខរៀង** **ទំព័រ**

**ផ្នែកទី១៖** អភិបាលកិច្ចប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ៣

**ផ្នែកទី២៖ ការបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត** ១៨

**ផ្នែកទី៣៖** ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧៖ ២៥

- សិទ្ធិ និងនីតិវិធី
- យុទ្ធនាការឃោសនាបោះឆ្នោត
- ថ្ងៃបោះឆ្នោត

**ផ្នែកទី៤៖** ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ៤៤

**ផ្នែកទី៥៖** យុវជន និងនយោបាយ ៤៨

យុវជនចូលរួមក្នុងការបង្កើនចំនួនស្ត្រីនៅថ្នាក់សម្រេចចិត្ត

# ផ្នែកទី១

## អភិបាលកិច្ចប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស




### ១. តើអភិបាលកិច្ចប្រជាធិបតេយ្យមានន័យដូចម្តេច?

អភិបាលកិច្ចប្រជាធិបតេយ្យ និយាយទៅដល់អភិបាលកិច្ចល្អ បន្ថែមជាមួយគោលការណ៍ បទដ្ឋាន និងស្ថាប័នប្រជាធិបតេយ្យ ដែលមានន័យថា ៖

- សិទ្ធិមនុស្ស និងមូលដ្ឋានសេរីភាពត្រូវបានគោរព
- ប្រជាពលរដ្ឋមានមតិក្នុងការសម្រេចចិត្ត
- ប្រជាពលរដ្ឋមានសិទ្ធិស្មើភាពប្រាសចាកពីការរើសអើង ហើយស្ត្រីគឺជាដៃគូស្មើភាពជាមួយបុរស ។
- សេចក្តីត្រូវការរបស់មនុស្សជំនាន់ក្រោយត្រូវបានដាក់បញ្ចូលក្នុងគោល-

នយោបាយបច្ចុប្បន្ន។

- គោលនយោបាយ សេដ្ឋកិច្ច និងសង្គម ឆ្លើយតបសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ។

អភិបាលកិច្ចប្រជាធិបតេយ្យមានក្របខ័ណ្ឌដែលគ្របដណ្ដប់លើវិស័យចំនួនប្រាំពីរ ÷

១. អភិវឌ្ឍភាព

២. ប្រពន្ធ័ និងដំណើរការបោះឆ្នោត

៣. សិទ្ធិមនុស្ស

៤. យុត្តិធម៌

៥. ការទទួលបាន និងការប្រើប្រាស់ព័ត៌មាន និងការផ្សព្វផ្សាយ

៦. វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន

៧. កំណែទំរង់រដ្ឋបាលសាធារណៈ និងការប្រឆាំងអំពើពុករលួយ

## ២. អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យ?

**លទ្ធិ** : របប ការនិយម ការយល់ឃើញ

**ប្រជា** : ប្រជាជន ប្រជាពលរដ្ឋ

**អធិបតី ឬ អធិបតេយ្យ** : ធំ សម្បើម ក្រៃលែង

លទ្ធិប្រជាធិបតេយ្យជាទម្រង់នៃការដឹកនាំប្រទេសដែលអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋពិតប្រាកដ ។ អំណាចកំពូលក្នុងរដ្ឋ ពិសេស សភា និងរដ្ឋាភិបាលស្ថិតក្នុងកណ្ដាប់ដៃប្រជាពលរដ្ឋ ប្រើប្រាស់ដោយប្រជាពលរដ្ឋផ្ទាល់ ឬ/និងដោយអ្នកតំណាងប្រជា-ពលរដ្ឋដែលជ្រើសរើសដោយប្រជាពលរដ្ឋតាមរយៈការបោះឆ្នោត។ អ្វីៗដែលរដ្ឋាភិបាល និងតំណាងរាស្ត្រធ្វើ គឺត្រូវស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ និងដើម្បីផ្ដល់ផលប្រយោជន៍

ទៅប្រជាពលរដ្ឋ។ នៅក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានអំណាច មានសិទ្ធិសេរីភាពច្រើនបំផុត ។

ជាទស្សនៈទូទៅ រដ្ឋាភិបាល និងរដ្ឋសភាប្រជាធិបតេយ្យ ជារដ្ឋាភិបាល និងសភាដែលកើតឡើងដោយប្រជាពលរដ្ឋ ជារបស់ប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ ។

### ៣. ប្រជាធិបតេយ្យត្រូវបានគេចែកចេញជាប៉ុន្មានប្រភេទ?

ប្រជាធិបតេយ្យ បែងចែកជា**បីប្រភេទ** គឺ *ប្រជាធិបតេយ្យដោយផ្ទាល់ ប្រជាធិបតេយ្យតាមរយៈតំណាង* និង *ប្រជាធិបតេយ្យស្រុះស្រួលជាឯកច្ឆន្ទ*។

ក) ***ប្រជាធិបតេយ្យដោយផ្ទាល់ ឬប្រជាធិបតេយ្យសុទ្ធសាធ*** គឺប្រជាពលរដ្ឋគ្រប់រូបអាចចូលរួមក្នុងការអនុម័តសេចក្តីសំរេចដោយផ្ទាល់ ឬអនុវត្តសកម្មភាពការងារជាសាធារណៈដោយប្រជាពលរដ្ឋខ្លួនឯង គឺមិនតាមរយៈមន្ត្រីដែលខ្លួនជ្រើសតាំង ឬតែងតាំងឡើយ ។

**ឧទាហរណ៍** : ការធ្វើប្រជាមតិក្នុងការសំរេចអនុមត័ច្បាប់ ឬគោលការណ៍អ្វីមួយ ។

ខ) ***ប្រជាធិបតេយ្យតាមរយៈតំណាង ឬ ប្រជាធិបតេយ្យដោយប្រយោល*** តាមរយៈការបោះឆ្នោតជ្រើសរើសអ្នកតំណាងដោយប្រជាពលរដ្ឋ ដើម្បីឱ្យមកធ្វើសេចក្តីសំរេចចិត្តផ្នែកនយោបាយ រៀបចំច្បាប់ និងគោលនយោបាយសំរាប់ផលប្រយោជន៏សាធារណៈ ។ ប្រជាធិបតេយ្យតាមរយៈតំណាងនេះ ត្រូវបានគេយកមកអនុវត្តដោយសារតែភាពធំធេង និងសាំញ៉ាំរបស់សង្គមនៅសម័យបច្ចុប្បន្ន ។

**ឧទាហរណ៍**: ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។

***គ) ប្រជាធិបតេយ្យស្រុះស្រួលជាឯកច្ឆន្ទ័ (Consensus) :*** គឺការអនុវត្តដោយការសំរេចតាមរយៈស្រុះស្រួលជាឯកច្ឆន្ទ័។ លក្ខណៈនៃការសំរេចចិត្ត គឺផ្តល់ភាពទូលំទូលាយរហូតដល់មតិប្រឆាំង មតិភាគតិច។

**ឧទាហរណ៍:** ប្រជាធិបតេយ្យស្រុះស្រួលជាឯកច្ឆន្ទ័ (Consensus Democracy) ត្រូវបានអនុវត្តនៅក្នុងប្រទេសស្វីស ហ្វាំងឡង់ និងប៊ែលហ្សិក ដែលបានបង្កើតវប្បធម៌នយោបាយស្រុះស្រួលជាឯកច្ឆន្ទ័ ដោយខិតខំទប់ស្កាត់ការត្រួតត្រាផ្តាច់មុខនៃក្រុមមតិភាគច្រើន។

### ៤. តើធាតុសំខាន់ៗនៅក្នុងប្រជាធិបតេយ្យមានអ្វីខ្លះ?

ធាតុសំខាន់ៗរបស់ប្រជាធិបតេយ្យ ៖

- **សេរីភាពបញ្ចេញមតិ សារព័ត៌មាន និងការប្រជុំ** : ប្រជាពលរដ្ឋមានសិទ្ធិបង្កើតសារព័ត៌មាន វិទ្យុ ទូរទស្សន៍ មានសិទ្ធិទទួល និងផ្សព្វផ្សាយព័ត៌មាន សេរីភាពបង្កើតគណបក្សនយោបាយ អង្គការសង្គម គណៈវិជ្ជាជីវៈ សេរីភាពក្នុងការប្រជុំ និងសេរីភាពធ្វើបាតុកម្ម និងកូដកម្មដោយសន្តិវិធី។
- **ការបោះឆ្នោត** ដោយសេរី យុត្តិធម៌ សម្ងាត់ និងទៀងទាត់
- **ការផ្ទេរអំណាច** : អ្នកចាញ់ផ្ទេរអំណាចទៅឱ្យអ្នកឈ្នះដោយសន្តិវិធី
- **ពហុនិយម និងការអធ្យាស្រ័យ** : ការសំរេចអ្វីមួយយកតាមសំលេងភាគច្រើន និងគោរព ពិចារណាលើមតិភាគតិច ។
- **ការបែងចែកអំណាច** (អំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ អំណាចតុលាការ): **អំណាច**ត្រូវបែងចែកដាច់ៗពីគ្នា ដោយមិនអនុញ្ញាតឱ្យបុគ្គល ឬស្ថាប័នណាមួយមានអំណាចហួសហេតុ គ្មានការត្រួតពិនិត្យនោះឡើយ។ ការបែងចែកអំណាចសំដៅជាពិសេសដល់ការធានានូវឯករាជភាពរបស់តុលាការ ។

- **អំណាចនីតិបញ្ញត្តិ** (រដ្ឋសភា និងព្រឹទ្ធសភា)៖ មានមុខនាទីតាក់តែងច្បាប់អនុម័តច្បាប់ និងគោលនយោបាយផ្សេងៗ និងត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល។
- **អំណាចនីតិប្រតិបត្តិ** (រដ្ឋាភិបាល)៖ មានមុខនាទីអនុវត្តច្បាប់ ធ្វើសេចក្តីព្រាងច្បាប់ ដឹកនាំការងារប្រចាំថ្ងៃរបស់រដ្ឋាភិបាល និងអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចំរើន។
- **អំណាចតុលាការ** ៖ មានមុខនាទីធានាការគោរពច្បាប់ ផ្តល់យុត្តិធមិសង្គម និងផ្តន្ទាទោសជនណាដែលរំលោភច្បាប់ ។

ការបែងចែកអំណាច ជាគោលនយោបាយមួយសំរាប់វាស់ពីក៏រិតការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការត្រួតពិនិត្យតុល្យភាពនៃអំណាចទាំងការអនុមត័ និងអនុវត្តច្បាប់។

- ♦ **ការចូលរួមរបស់ប្រជាពលរដ្ឋ** ៖ ការសំរេចចិត្តនានា រួមទាំងការបង្កើតច្បាប់ត្រូវមានការចូលរួមយោបល់ពីប្រជាពលរដ្ឋ និងយកទៅផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានយល់ដឹង និងអនុវត្ត ។
- ♦ **តម្លាភាព** ៖ ដំណើរការដែលធ្វើឱ្យមានព័តិមានពេញលេញដោយសេរី
- ♦ **នីតិរដ្ឋ** ៖ រដ្ឋគោរពច្បាប់ រដ្ឋដែលយកច្បាប់ជាធំ ឬដែលមានរដ្ឋាភិបាលគ្រប់គ្រងតាមអំណាចនៃច្បាប់ គឺមិនមែនតាមអំណាចបុគ្គល ឬ ក្រុមបុគ្គលណាមួយឡើយ។ មន្ត្រីនគរបាល និងតុលាការត្រូវមានវិជ្ជាជីវៈច្បាប់ពិតប្រាកដ ទាំងរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋត្រូវចូលរួមគោរពច្បាប់ទាំងអស់គ្នាដោយស្មើភាព ។

### ៥. អ្វីខ្លះជាការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (Democratic Development)?

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាព
- ការពិគ្រោះយោបល់ និងការចូលរួម
- ឆ្លើយតប និងគណនេយ្យភាព
- លើកស្ទួយសមធម៌ (យកចិត្តទុកដាក់ពិសេស ស្ត្រី បុរស យុវជន កុមារ ប្រជាពលរដ្ឋក្រីក្រ ជនពិការ និងជនជាតិដើមភាគតិច)។
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

### ៦. អ្វីទៅហៅថាប្រជាធិបតេយ្យូបនីយកម្ម (Democratization)?

ប្រជាធិបតេយ្យូបនីយកម្ម គឺជាអន្តរកាលឆ្ពោះទៅរបបប្រជាធិបតេយ្យពេញលេញ។ មូលហេតុនាំឱ្យមានអន្តរកាល ឬក្នុងដំណើរការប្រជាធិបតេយ្យូបនីយកម្ម គឺបណ្តាលមកពីកត្តាសំខាន់ៗដូចជា ការអប់រំ វណ្ណៈ សង្គមស៊ីវិល ការអន្តរាគមនៃបរទេស មូលធននិយម ។ល។ និង ។ល។

### ៧. អ្វីខ្លះជាប្រជាធិបតេយ្យមានលក្ខណៈពេញលេញ?

ប្រជាធិបតេយ្យត្រូវការឱ្យមានពហុភាព ព្រោះថា មនុស្ស និងក្រុមមនុស្សយើងតែងតែមានជំនឿ និងគំនិតប្លែកៗពីគ្នា។ មនុស្សដែលរស់នៅក្នុងសង្គមប្រជាធិបតេយ្យមិនត្រូវគិតថាមានតែក្រុមខ្លួនទេដែលឈ្នះរហូត ឬថាមានតែក្រុមខ្លួនទេដែលមានគំនិតល្អលើសគេនោះ ពោលគឺត្រូវគិតថា នៅមានក្រុមដទៃទៀតដែលអាចនឹងឈ្នះខ្លួននៅពេលក្រោយ ហើយនៅមានគំនិតនៃក្រុមដទៃទៀតដែលអាចនឹងល្អជាងយើងផងដែរ។ ច្បាប់

មតិភាគច្រើនត្រូវតែឈ្នះ និងត្រូវតែការពារគំនិត និងទស្សនៈភាគតិចផង ក៏ដូចគ្នានឹងគណបក្សចាញ់ឆ្នោតត្រូវតែប្រគល់អំណាចទៅគណបក្សដែលឈ្នះឆ្នោតជាដាច់ខាត ព្រោះថាការប្រគល់អំណាចឱ្យនោះគ្រាន់តែជាកាប្រគល់ឱ្យបណ្ដោះអាសន្នតែប៉ុណ្ណោះ ។គណបក្សចាញ់អាចមានឱកាសត្រឡប់មកកាន់អំណាចវិញនៅពេលបោះឆ្នោតឈ្នះលើកក្រោយ ។

*គោលការណ៍ទាំងនេះជាខ្នាតគំរូអន្តរជាតិសំរាប់ឱ្យប្រជាធិបតេយ្យមានលក្ខណៈពេញលេញ :*

(១) **មានការរួមចំណែកពីពលរដ្ឋ** : គឺពលរដ្ឋមិនត្រឹមតែមានសេរីភាព សិទ្ធិទេ ថែមទាំងមានកាតព្វកិច្ចទៀតផង ។ ការរួមចំណែករបស់ពលរដ្ឋក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ រួមមាន សេរីភាពបង្កើតសមាគម សហគមន៍ និងគណបក្សនយោបាយ សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះបោះឆ្នោត ការបង់ពន្ធដារ ប្រតិបត្តិតាមច្បាប់ និងការឃ្លាំមើលដំណើរការរបស់រដ្ឋាភិបាល សភា និងតុលាការ គឺជាកាតព្វកិច្ចរបស់ពលរដ្ឋដើម្បីជួយកែលំអការអនុវត្តប្រជាធិបតេយ្យ ។

(២) **មានការស្មើភាពគ្នា** : ក្នុងសង្គមប្រជាធិបតេយ្យ គោលការណ៍ស្មើភាពមានន័យថាមនុស្សគ្រប់រូបមានតំលៃ និងមានលទ្ធភាពដូចគ្នា ដោយគ្មានការរើសអើង ។

(៣) **មានការអនុគ្រោះគ្នា** : សង្គមប្រជាធិបតេយ្យ គឺជាសង្គមដែលប្រកបដោយសេចក្ដីអនុគ្រោះ។ មានន័យថា ក្នុងពេលដែលគណបក្សឈ្នះ សិទ្ធិគ្រប់គ្រងអំណាចពួកគេត្រូវអនុគ្រោះ និងទទួលស្គាល់សិទ្ធិគ្រប់បែបយ៉ាងរបស់មនុស្សភាគតិច(ឬគណបក្សដែលចាញ់) ។ ត្រូវអនុគ្រោះ និងអនុញ្ញាតឱ្យបក្សចាញ់ប្រើសិទ្ធិបញ្ចេញមតិជំទាស់ ។ រីឯនៅក្នុងសង្គមវិញ មនុស្សម្នាក់ក៏ត្រូវចេះអត់ឱនឱ្យគ្នាទៅវិញទៅមកផងដែរ ។

(៤) **មានការទទួលខុសត្រូវ** ៖ នៅក្នុងសង្គមប្រជាធិបតេយ្យ មន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ។ ពួកគេត្រូវបំពេញភារកិច្ចតាមឆន្ទៈប្រជា-ពលរដ្ឋ និងដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ ។

(៥) **មានតម្លាភាព** ៖ រឿងអ្វីៗដែលរដ្ឋាភិបាលធ្វើត្រូវតែឱ្យប្រជាពលរដ្ឋបានដឹងឮ នេះមានន័យថា ត្រូវអនុញ្ញាតឱ្យអ្នកកាសែត និងប្រជាពលរដ្ឋសាកសួរព័ត៌មាន អំពីកិច្ចការរបស់រដ្ឋាភិបាល ។

## ៨. ប្រពន្ធ័គ្រប់គ្រងរដ្ឋតាមរបបប្រជាធិបតេយ្យមានប៉ុន្មានយ៉ាង?

របបផ្តាច់ការ របបកុម្មុយនីស និងរបបហ្វាស៊ីស មិនមែនជារបបប្រជាធិបតេយ្យទេ។

**ប្រពន្ធ័គ្រប់គ្រងរដ្ឋតាមប្រជាធិបតេយ្យមាន ៣ យ៉ាង គឺ ៖**

- **ប្រពន្ធ័ប្រធានាធិបតីនិយម** ៖ ប្រធានាធិបតីត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ, មិនមាននាយករដ្ឋមន្ត្រីទេ ដូចជា សហរដ្ឋអាមេរិក, ហ្វីលីពីន, ឥណ្ឌូនេស៊ី ... (អំណាចសភា និងរដ្ឋាភិបាលដាច់ពីគ្នា) ។
- **ប្រពន្ធ័សភានិយម** ៖ រដ្ឋសភាត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជា-ពលរដ្ឋ ហើយរដ្ឋសភាបោះឆ្នោតទុកចិត្តនាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាលទាំងមូល ដូចជា*កម្ពុជា ជប៉ុន ថៃ អង់គ្លេស...*។ មានតែនាយករដ្ឋមន្ត្រី មិនមានប្រធានាធិបតីទេ (អំណាចសភា និងរដ្ឋាភិបាលមានតុល្យភាពគ្នា)។ ប្រពន្ធ័សភានិយមក៏មានប្រធានាធិបតីដែរ តែតួនាទីជាប្រធានរដ្ឋ មិនមែនប្រមុខរដ្ឋាភិបាលទេ ដូចជា ប្រទេសអាល្លឺម៉ង់មាននាយករដ្ឋមន្ត្រីជាប្រមុខរដ្ឋាភិបាល និងមានប្រធានាធិបតីជាប្រមុខរដ្ឋ (ដូចជាម្ចាស់ក្សត្រីរបស់ប្រទេសអង់គ្លេស) ។
- **ប្រពន្ធ័ចំរុះ ឬរបបពាក់កណ្តាលប្រធានាធិបតីនិយម** (Mixed-system or

Semi-presidential system) : ប្រធានាធិបតី ត្រូវបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ ចំណែកនាយករដ្ឋមន្ត្រីកើតចេញពីសមាជិកសភា (គណបក្សដែលឈ្នះឆ្នោតលំដាប់ទី១)។ បើប្រធានាធិបតី និងនាយករដ្ឋមន្ត្រីចេញពីគណបក្សតែមួយ អំណាចទាំងមូលធ្លាក់ទៅលើប្រធានាធិបតី (នាយករដ្ឋមន្ត្រីគ្រាន់តែជាជំនួយការប៉ុណ្ណោះ)។ ប៉ុន្តែបើប្រធានាធិបតី និងនាយករដ្ឋមន្ត្រីចេញពីគណបក្សផ្សេងគ្នា អំណាចត្រូវបែងចែកគ្នា ដូចជា បារាំង និងរុស្ស៊ី (មានប្រធានាធិបតីផង និងនាយករដ្ឋមន្ត្រីផង)។

### ៩. តើប្រទេសកម្ពុជាប្រកាន់យករបបនយោបាយ និងប្រព័ន្ធអ្វី?

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយ***ប្រជាធិបតេយ្យ សេរី ពហុបក្ស តាមប្រព័ន្ធសភានិយម***។

### ១០. តើអ្វីទៅជាប្រជាធិបតេយ្យសេរីដូចចែងក្នុងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា?

យោងតាមរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាមាត្រា៥១ថ្មី បានចែងថា " ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរី ពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងតុលាការ។

### ១១. តើអ្វីជាអត្ថន័យស្នូលនៃរបបប្រជាធិបតេយ្យសេរី ពហុបក្ស?

អត្ថន័យស្នូលនៃរបបប្រជាធិបតេយ្យសេរី ពហុបក្ស គឺអធិបតេយ្យភាពប្រជា-ពលរដ្ឋ។ អធិបតេយ្យភាពប្រជាពលរដ្ឋមានន័យថា អំណាចគ្រប់គ្រងរដ្ឋជារបស់ប្រជា-

ពលរដ្ឋ ហើយអំណាចនេះត្រូវតែកើតចេញពីប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ ដោយផ្អែកលើគោលការណ៍សេរីភាព និងសិទ្ធិស្វ័យសម្រេចរបស់ប្រជាពលរដ្ឋ។ អធិបតេយ្យភាពប្រជាពលរដ្ឋត្រូវបានរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ទទួលស្គាល់ និងបញ្ញត្តិក្នុងមាត្រា ៥១ វាក្យខ័ណ្ឌ២ និង៣។

**១២_តើអ្វីទៅជាការទទួលខុសត្រូវតាមខ្សែបណ្ដោយ**(Vertical Accountability)?

ការទទួលខុសត្រូវតាមខ្សែបណ្ដោយ គឺពលរដ្ឋទាមទារឱ្យមន្ត្រីសាធារណៈរបស់ពួកគាត់ទទួលខុសត្រូវចំពោះពួកគាត់។

ការទទួលខុសត្រូវតាមខ្សែបណ្ដោយមានពីរប្រភេទ:

**❈ ប្រភេទទី១:គណនេយ្យភាពនៃការបោះឆ្នោត(Electorial Accountability)**

- ប្រព័ន្ធគណបក្សនយោបាយ គឺត្រូវតែប្រកួតប្រជែង
- អ្នកបោះឆ្នោតត្រូវទទួលបានព័ត៌មានគ្រប់គ្រាន់ និងដឹងពីផល-ប្រយោជន៍របស់ខ្លួនច្បាស់លាស់។
- ការប្រកួតប្រជែង គឺត្រូវតែយុត្តិធម៌ ។ ដូច្នេះមន្ត្រីកាន់កាប់កិច្ចការរដ្ឋដែលជាប់ឆ្នោតត្រូវទទួលខុសត្រូវ និងត្រូវបានដកចេញពីតំណែងសម្រាប់សកម្មភាពមិនត្រឹមត្រូវ។

**❈ ប្រភេទទី២:** គណនេយ្យភាពសង្គម (Social Accountability)

- សង្គមស៊ីវិលពហុភាព សំបូរធនធាន និងឯករាជ្យពីរដ្ឋាភិបាល
- ប្រព័ន្ធផ្សព្វផ្សាយមហាជនត្រូវតែឯករាជ្យ និងមានវិជ្ជាជីវៈ
- សាធារណជនត្រូវចងក្រងគ្នា និងរស់រវើកក្នុងការតាមដានការប្រព្រឹត្តរបស់មន្ត្រីជាប់ឆ្នោត ដូច្នេះកម្មវិធីនយោបាយដែលគ្មាន

ប្រសិទ្ធភាព និងការរំលោភអំណាចត្រូវបានសើរើឡើងវិញ ។

**១៣. តើអ្វីទៅជាគណនេយ្យភាពតាមខ្សែទទឹង** (Horizontal Accountability)?

- អំណាចត្រូវបានបែងចែក និងបំបែកក្នុងចំណោម ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នឯករាជ្យដទៃទៀត (Checks and Balance) ។

- អំណាចនីតិប្រតិបត្តិត្រូវបានកំណត់ ទប់ស្កាត់ និងពិនិត្យពិច័យលំអិតដោយនីតិបញ្ញត្តិឯករាជ្យ តុលាការឯករាជ្យ និងស្ថាប័នដទៃទៀតដែលឯករាជ្យ ។

- ស្ថាប័នឯករាជ្យដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងលើអំពើពុករលួយ និងការរំលោភអំណាច ។

ឧទាហរណ៏: - គណៈកម្មាធិការប្រឆាំងអំពើពុករលួយ

- គណៈកម្មាធិការទទួលពាក្យបណ្តឹងសាធារណៈ(Ombadsman)
- គណៈកម្មាធិការស៊ើបអង្កេតរបស់សភា
- អាជ្ញាធរសវនកម្មជាតិ

**១៤. តើអ្វីទៅជានីតិរដ្ឋ?**

- គោលការណ៍នីតិរដ្ឋ គឺការធានាការពារសិទ្ធិសេរីភាពរបស់បុគ្គល ការគាំពារសិទ្ធិពលរដ្ឋ ការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងការកម្រិតអំណាចរបស់រដ្ឋាភិបាល ។

- គ្រប់ពលរដ្ឋទាំងអស់ស្មើគ្នាចំពោះមុខច្បាប់
- គ្មានការចាប់ខ្លួនតាមអំពើចិត្ត ការនិរទេសខ្លួន ឬក៏ការចាប់ដាក់គុក
- គ្មាននរណាម្នាក់ស្ថិតនៅលើច្បាប់

- អំណាចរដ្ឋាភិបាលត្រូវបានកំរិត (មានដែនកំណត់) គ្មានមន្ត្រីណាម្នាក់អាចល្មើសការកម្រិតរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងនេះបានទេ។
- តុលាការត្រូវឯករាជ្យទាំងរចនាសម្ព័ន្ធ និងការអនុវត្តន៍ជាក់ស្តែង
- សិទ្ធិទទួលបានការដឹងឮពីការចោទប្រកាន់ប្រឆាំងខ្លួន
- សិទ្ធិទទួលបានការសន្មត់ថា ជាជនគ្មានទោស(Presumption of Innocence)
- គ្មានជនណាម្នាក់ត្រូវបានពិន័យ ឬក៏កាត់ទោស លើកលែងតែក្នុងករណីច្បាប់ចែងជាមុន។
- គ្មាននរណាម្នាក់ត្រូវបានទទួលរងទារុណកម្ម ឬក៏ការប្រព្រឹត្តព្រៃផ្សៃ និងអមនុស្សធម៌នោះទេ។

## ១៥. ប្រទេសដែលមាននីតិរដ្ឋ ត្រូវមានលក្ខខណ្ឌចាំបាច់អ្វីខ្លះ?

ប្រទេសដែលមាននីតិរដ្ឋ លុះត្រាតែប្រទេសនោះប្រកបដោយលក្ខខណ្ឌចាំបាច់ដូចតទៅ :

- ត្រូវមានតុលាការប្រកបដោយសមត្ថភាព វិជ្ជាជីវៈ ឥតលំអៀង និងឯករាជ្យពិតប្រាកដ មិនស្ថិតក្រោមអំណាចបុគ្គល ឬក្រុមណាមួយ។
- អ្នកគ្រប់គ្រងត្រូវប្រើប្រាស់អំណាចខ្លួនឱ្យស្របទៅតាមច្បាប់ មិនរំលោភអំណាច ឬយកអំណាចនោះទៅប្រើប្រាស់ដើម្បីផលប្រយោជន៍ខ្លួន និងបក្សពួក ថែមទាំងមិនជ្រៀតជ្រែកទៅក្នុងការងារតុលាការជាដើម។
- ត្រូវមានរដ្ឋធម្មនុញ្ញចែងទុកជាមុន អំពីការប្រើសិទ្ធិពេញលេញក្នុងការត្រួត-ពិនិត្យអំណាចនីតិប្រតិបត្តិ និងរដ្ឋបាល ដើម្បីកុំឱ្យអំណាចទាំងនេះរំលោភច្បាប់។
- ប្រជាពលរដ្ឋត្រូវមានសមភាពចំពោះមុខច្បាប់ទាំងអស់គ្នា មានន័យថាប្រជាពលរដ្ឋគ្រប់រូប គ្រប់ជាន់ថ្នាក់ ត្រូវមានសិទ្ធិយករឿងក្តីខ្លួនទៅប្តឹងផ្តល់ដល់សាលា

ជម្រះក្តី និងបានទទួលការវិនិច្ឆ័យដោយយុត្តិធម៌ដូចៗគ្នា។

- សេរីភាពសារព័ត៌មាន : ប្រជាពលរដ្ឋត្រូវទទួលសិទ្ធិ និងសេរីភាពយ៉ាងពេញលេញក្នុងការបញ្ចេញមតិ យោបល់ បង្កើតអង្គការសារព័ត៌មាន ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ជាលក្ខណៈឯកជន ។

## ១៦. សិទ្ធិមនុស្សជាមូលដ្ឋានមានអ្វីខ្លះ?

### ក. សិទ្ធិពលរដ្ឋ :

- សិទ្ធិរស់រានមានជីវិត
- សេរីភាពខាងជំនឿ និងមនសិការផ្ទាល់ខ្លួន
- សេរីភាពក្នុងការបញ្ចេញមតិ និងចូលរួមសមាគម
- សិទ្ធិធ្វើដំណើរដោយសេរី (ប៉ុន្តែបើចូលទៅប្រទេសដទៃត្រូវមានការអនុញ្ញាតពីអាជ្ញាធរនៃប្រទេសនោះ) ។
- សិទ្ធិតាំងទីលំនៅដោយសេរី (ប៉ុន្តែត្រូវឱ្យសមស្របតាមច្បាប់សំណង់)
- សិទ្ធិការពារការរំលោភបំពានលើរាងកាយ និងផ្លូវចិត្ត
- ភាពស្មើគ្នាចំពោះមុខច្បាប់ និងតាមផ្លូវតុលាការ
- សិទ្ធិការពារការឆែកឆេរលំនៅដ្ឋានខុសច្បាប់
- សិទ្ធិរួចចាកផុតពីអំណាចផ្តាច់ការរបស់រដ្ឋាភិបាល និងមានការការពារពីច្បាប់។

### ខ. សិទ្ធិនយោបាយ :

- សេរីភាពក្នុងការនិយាយស្តី សារព័ត៌មាន ប្រជុំធ្វើសេចក្តីតវ៉ា
- សិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត

- សិទ្ធិចូលរួមបោះឆ្នោតដោយសេរី តាមឆន្ទៈ និងគ្មានការភ័យខ្លាច
- សេរីភាពបង្កើតសមាគម ឬ គណបក្សនយោបាយ
- សិទ្ធិចូលរួមក្នុងឆាកនយោបាយ (សិទ្ធិធ្វើយុទ្ធនាការសម្រាប់គណបក្សនយោបាយ សិទ្ធិចូលរួមក្នុងគណបក្សនយោបាយ និងសិទ្ធិលាឈប់ពីសមាជិកគណបក្សនយោបាយ) ។
- សិទ្ធិមានលទ្ធភាពស្មើគ្នាចំពោះសេវាកម្មសាធារណៈ (រួមទាំងសិទ្ធិទទួលការជ្រើសរើសឱ្យកាន់តំណែងការងារ) ។

**គ. សិទ្ធិសេដ្ឋកិច្ច និងសង្គម :**

- សិទ្ធិមានកម្មសិទ្ធិផ្ទាល់ខ្លួន (ការដាក់ជាសម្បត្តិរួមដូចសម័យខ្មែរក្រហម គឺជាការរំលោភ) ។
- សិទ្ធិទទួល (ដោយទិញជូន ឬអំណោយប្រើប្រាស់ ផ្ទេរ និងឱ្យទៅគេដោយលក់ដូរ ឬធ្វើអំណោយ ឬបោះបង់ចោលនូវទ្រព្យសម្បត្តិ) ។
- សិទ្ធិជ្រើសរើសការងារ ឬផ្លាស់ប្តូរការងារ (មិនបង្ខំឱ្យធ្វើការងារដោយផ្ទុយនឹងឆន្ទៈ ឬផ្ទុយពីសមត្ថភាព និងមុខជំនាញឡើយ) ។
- សិទ្ធិចូលរួមក្នុងសហជីព សមាគមវិជ្ជាជីវៈ សិទ្ធិធ្វើមុខជំនួញ និងសិទ្ធិធ្វើកិច្ចសន្យាស្របច្បាប់ ។
- សិទ្ធិមានម្ហូបអាហារគ្រប់គ្រាន់
- សិទ្ធិមានគ្រួសារ និងគូស្រករ
- សិទ្ធិមានសន្តិសុខសង្គម
- សិទ្ធិមានពេលសំរាក និងកំសាន្តកាយ (ជនណាក៏ដោយមានសិទ្ធិធ្វើការមាន

កំណត់ពេលម៉ោងត្រឹមត្រូវ និងមានពេលសំរាកកំសាន្ត) ។

- សិទ្ធិទទួលការអប់រំ ( មនុស្សគ្រប់រូបត្រូវតែមានចំណេះដឹង។ សង្គម និងរដ្ឋមានកាតព្វកិច្ចចាំបាច់ធ្វើឱ្យពលរដ្ឋគ្រប់រូបបានរៀនសូត្រ) ។

### ឃ. សិទ្ធិវប្បធម៌ :

- សិទ្ធិដើម្បីមានចំណេះដឹង និងសិទ្ធិអាស្រ័យផលវប្បធម៌ និងរក្សាសិទ្ធិ
- សិទ្ធិនិយាយភាសាដើមរបស់ខ្លួន និងសិទ្ធិប្រកាន់ទំនៀមទម្លាប់ ប្រពៃណី ជំនឿសាសនារបស់ខ្លួន ។



### ង. សិទ្ធិមានបរិស្ថាន និងសិទ្ធិអភិវឌ្ឍន៍

- សិទ្ធិរស់នៅក្នុងបរិស្ថានមួយបរិសុទ្ធ
- សិទ្ធិការពារការបំផ្លិចបំផ្លាញបរិស្ថាន និងសិទ្ធិអភិវឌ្ឍន៍សហគមន៍។

# ផ្នែកទី២

## ការបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត

### ១៧. អ្វីគឺជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌?

**ការបោះឆ្នោតដោយសេរី :**

គឺនិយាយទៅដល់សេរីភាព សិទ្ធិ ឱកាស និងលទ្ធភាព។



- **ការបោះឆ្នោត និងសិទ្ធិចូលរួមបោះឆ្នោត**

- ពុំមានពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ត្រូវបានគេបដិសេធមិនឱ្យបោះឆ្នោត ឬត្រូវបានបង្កការលំបាកក្នុងការបោះឆ្នោតដែលបាត់បង់ឱកាសបោះឆ្នោត។
- អ្នកបោះឆ្នោតមានសិទ្ធិស្មើគ្នានៅក្នុងស្ថានីយ៍ ឬការិយាល័យបោះឆ្នោតដើម្បីប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួន។
- សិទ្ធិបោះឆ្នោតជាសំងាត់ ជាសិទ្ធិដាច់ខាត
- អ្នកបោះឆ្នោតគ្រប់រូបត្រូវមានលទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ហើយមានសំលេងស្មើគ្នានឹងសំលេងឆ្នោតរបស់អ្នកឯទៀត។
- ប្រជាពលរដ្ឋពេញវ័យគ្រប់រូបមានសិទ្ធិបោះឆ្នោតដោយគ្មានការរើសអើង សាសនា ពណ៌សម្បុរ និងស្ថានភាពនៅក្នុងសង្គម។
- អ្នកបោះឆ្នោតអាចទទួលព័ត៌មានអំពីដំណើរការបោះឆ្នោតដោយសេរី និងគ្រប់ដំណើរការនៃការបោះឆ្នោត។

- មានការចូលរួមប្រជុំដោយសេរី និងការបញ្ចេញមតិយោបល់ ដើម្បីពិភាក្សាអំពីបេក្ខជន បេក្ខនារី និងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។
- អ្នកបោះឆ្នោតសំរេចចិត្តបោះឆ្នោតតាមឆន្ទៈរបស់ខ្លួនពិតប្រាកដ ដោយគ្មានការគំរាមកំហែង គ្មានការបង្ខំឱ្យបោះឆ្នោតគាំទ្រគណបក្សណាមួយ គ្មានការទិញសន្លឹកឆ្នោត គ្មានអំពើហឹង្សា ។

## ▪ ដំណើរការបោះឆ្នោត បេក្ខជន និងគណបក្សនយោបាយ

- ប្រជាពលរដ្ឋមានសិទ្ធិ និងឱកាសស្មើគ្នាក្នុងការឈរឈ្មោះជាបេក្ខជន ។ បេក្ខជនគ្រប់រូប និងគណបក្សទាំងអស់ត្រូវមានឱកាសស្មើគ្នា ដើម្បីប្រើប្រាស់ប្រពន្ធ័ឃោសនា និងមានសិទ្ធិក្នុងបញ្ហាសន្តិសុខដោយគ្មានការគំរាមកំហែង ការបំភិតបំភ័យ និងមានសិទ្ធិធ្វើសកម្មភាពឃោសនាដោយសេរី គ្មានការរារាំង ការរំខាន និងមានសុវត្ថិភាព ។ គណបក្សអាចពង្រីកបណ្តាញ និងជ្រើសរើសសមាជិកសកម្មជនដោយសេរី ។
- បុគ្គលគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិឱ្យច្បាប់ការពារ ហើយមានសិទ្ធិឱ្យមានការដោះស្រាយការរំលោភនានាលើសិទ្ធិនយោបាយ និងសិទ្ធិបោះឆ្នោត ។

## ▪ អ្នកសង្កេតការណ៍

- អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងភ្នាក់ងាររបស់គណបក្សនយោបាយត្រូវបានផ្តល់សិទ្ធិដើម្បីចូលរួមសង្កេតការណ៍ តាមដាន និងធ្វើរបាយការណ៍លើរាល់សកម្មភាពនៃដំណើរការបោះឆ្នោតបានដោយសេរី ទូលំទូលាយ និងគោរព

ទៅតាមក្រមប្រតិបត្តិរបស់អ្នកសង្កេតការណ៍ ។

**ការបោះឆ្នោតដោយយុត្តិធម៌:**

គឺនិយាយទៅដល់ការទទួលខុសត្រូវ និងកាតព្វកិច្ច ។

- មិនមានការក្លែងបន្លំសន្លឹកឆ្នោត ឬការលួចដូរសន្លឹកឆ្នោត គ្មានការប្រើប្រាស់មធ្យោបាយទុច្ចរិតផ្សេងៗ ។
- អាជ្ញាធររៀបចំការបោះឆ្នោតឯករាជ្យ អព្យាក្រឹត ស្អាតស្អំ តម្លាភាព និងមានការជឿជាក់ពីសាធារណជន និងការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់រៀបចំការបោះឆ្នោត ។
- ការដោះស្រាយវិវាទបោះឆ្នោតមានភាពយុត្តិធម៌ ត្រឹមត្រូវតាមច្បាប់ មានតម្លាភាព ។ សាធារណជនយល់ដឹងអំពីនីតិវិធីដោះស្រាយវិវាទបោះឆ្នោត និងច្បាប់មានន័យគ្រប់គ្រាន់សម្រាប់អនុវត្តការដោះស្រាយ ។
- បង្កើតលក្ខខណ្ឌប្រកួតប្រជែងសម្រាប់បោះឆ្នោតដោយផ្អែកលើមូលដ្ឋានដែលមាន "សមធម៌" ។
- បង្កើតនីតិវិធីដ៏មានប្រសិទ្ធភាពដោយមានការចូលរួមពីភាគីដែលពាក់ព័ន្ធ ឥតលំអៀង និងឥតមានការរើសអើងសម្រាប់ការចាត់ចែងការបោះឆ្នោត ពិសេសការចុះឈ្មោះបោះឆ្នោត និងការឃោសនាបោះឆ្នោត ។
- ធានាឱ្យបាននូវភាពទៀងត្រង់ និងនីយតភាព( ការបោះឆ្នោតត្រូវធ្វើឡើងដោយទៀងទាត់ក្នុងរយៈពេលកំណត់ប្រាំឆ្នាំម្តង) នៃការអនុវត្តក្របខ័ណ្ឌច្បាប់បោះឆ្នោត ពិសេសថ្ងៃបោះឆ្នោតការពារមិនឱ្យមានអ្នកបោះឆ្នោតណាម្នាក់បោះឆ្នោត បានច្រើនលើក ឬការបោះឆ្នោតដោយជនទាំងឡាយណាដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។
- ធានាឱ្យគណបក្ស បេក្ខជន និងអ្នកគាំទ្រទទួលបានការការពារ និងមានសន្តិសុខ

ដូចៗគ្នា។

**១៨. លក្ខណៈបែបណាខ្លះដែលជាការបោះឆ្នោតដោយស្មើភាព?**

- គណបក្សនយោបាយ និងបេក្ខជនទាំងអស់មានឱកាសស្មើគ្នាក្នុងការប្រកួតប្រជែងបោះឆ្នោត
- នៅអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត គណបក្សនយោបាយចូលរួមប្រកួតប្រជែងទាំងអស់ស្មើភាពគ្នាក្នុងការប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយរដ្ឋ ដូចជា ទូរទស្សន៍ វិទ្យុ មានសិទ្ធិប្រើសេវាសាធារណៈដូចៗគ្នា អាចប្រើសិទ្ធិរួមប្រជុំមហាជនតាមកន្លែងសាធារណៈតាមគ្រប់រូបភាព និងមធ្យោបាយដោយស្មើភាពគ្នា ដើម្បីបង្ហាញពីកម្មវិធីនយោបាយ និងសមត្ថភាពរបស់ខ្លួនជូនប្រជាពលរដ្ឋ។
- អ្នកបោះឆ្នោតមានសិទ្ធិបោះឆ្នោតបានតែ១ដងគត់ ស្មើនឹង១សន្លឹក ក្នុង១អាណត្តិ ។ សន្លឹកឆ្នោត១សន្លឹកមានតម្លៃស្មើគ្នានៅគ្រប់មណ្ឌលបោះឆ្នោត ខេត្ត ក្រុង ឃុំ សង្កាត់ទាំងអស់ ទោះបីអ្នកបោះឆ្នោតមានឋានៈជានាយករដ្ឋមន្ត្រី អភិបាលខេត្ត អភិបាលស្រុក ជាព្រះសង្ឃ ជាមេឃុំ ឬប្រជាពលរដ្ឋសាមញ្ញក៏ដោយ។

**១៩. នៅពេលមានការផ្លាស់ប្តូររដ្ឋាភិបាលតាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌ តើប្រទេសអាចកើតមានសង្គ្រាម ឬអស្ថេរភាពដែរឬទេ?**

**ទេ! ប្រទេសមិនអាចកើតមានសង្គ្រាម ឬអស្ថេរភាពជាដាច់ខាត!** ពីព្រោះសង្គមប្រជាធិបតេយ្យដែលមានការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ពិតប្រាកដ មានការជឿទុកចិត្តពីគ្រប់ភាគីពាក់ព័ន្ធ ពិសេសគណបក្សចូលរួមប្រកួតប្រជែង អ្នកចាញ់ គឺចាញ់ដោយពេញចិត្ត ហើយអ្នកឈ្នះគឺឈ្នះដោយកិត្តិយស ភាពត្រឹមត្រូវ និងថ្លៃថ្នូរ។ ដូច្នេះ

គណបក្សចាញ់ឆ្នោតនឹងប្រគល់អំណាចទៅឱ្យគណបក្សឈ្នះឆ្នោតដោយសន្តិវិធី ។ ច្បាប់មតិភាគច្រើនត្រូវតែឈ្នះ និងត្រូវតែការពារគំនិត និងទស្សនៈភាគតិចផង ព្រោះថាការប្រគល់អំណាចឱ្យនោះគ្រាន់តែជាកាប្រគល់ឱ្យបណ្ដោះអាសន្នតែប៉ុណ្ណោះ ។ គណបក្សចាញ់អាចមានឱកាសត្រឡប់មកកាន់អំណាចវិញនៅពេលបោះឆ្នោតឈ្នះលើកក្រោយ ។

## ២០. តើអ្នកបោះឆ្នោតប្រើប្រាស់សិទ្ធិអំណាចយ៉ាងណាចំពោះតំណាងរាស្ត្រ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណបក្សជាប់ឆ្នោត?

- ក្រោយពេលបោះឆ្នោត អ្នកបោះឆ្នោតត្រូវតែតាមដាន សង្កេត និងវាយតម្លៃលើសកម្មភាព និងការអនុវត្តការសន្យារបស់អ្នកតំណាងជាប់ឆ្នោតរបស់ខ្លួន និងគណបក្សជាប់ឆ្នោត ។ អ្នកតំណាងដែលជាប់ឆ្នោត (តំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់) បានទទួលអំណាចពីប្រជាពលរដ្ឋតាមរយៈការបោះឆ្នោតត្រូវតែបំរើផលប្រយោជន៍ និងបំពេញសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ។
- បើអ្នកតំណាងជាប់ឆ្នោតមិនបានបំរើផលប្រយោជន៍ប្រជាពលរដ្ឋ មិនអនុវត្តតាមការសន្យារបស់ខ្លួន ប្រជាពលរដ្ឋអាចប្រើប្រាស់អំណាចរបស់ខ្លួន ដោយស្នើសុំឱ្យអ្នកតំណាងនោះគោរពការសន្យារបស់ខ្លួន ឬសុំឱ្យអ្នកតំណាងនោះលាចេញពីតំណែងមុនពេលកំណត់ ឬប្រជាពលរដ្ឋអាចធ្វើពាក្យបណ្ដឹងទៅសាមីគណបក្សនយោបាយនៃអ្នកតំណាងនោះនៅអាណត្តិក្រោយឱ្យធ្វើការផ្លាស់ប្ដូរអ្នកតំណាងរូបនោះចេញ ឬជំរើសចុងក្រោយប្រជាពលរដ្ឋមិនបោះឆ្នោតគាំទ្រអ្នកតំណាងរូបនោះ ឬគណបក្ស នយោបាយរបស់អ្នកតំណាងនោះ ហើយប្រជាពលរដ្ឋបោះឆ្នោតឱ្យអ្នកតំណាងថ្មីផ្សេងទៀតដែលខ្លួនពេញចិត្ត សង្ឃឹមថាអាចដោះស្រាយបញ្ហាយើងបាន ។

♦ ប្រសិនបើកំហុសរបស់អ្នកតំណាង (ជាបុគ្គល ឬគណបក្សនយោបាយ) មាន លក្ខណៈធ្ងន់ធ្ងរ ដូចជា ការកេងប្រវ័ញ្ចជាតិ អំពើពុករលួយធ្ងន់ធ្ងរមិនដោះ-ស្រាយបញ្ហាជាតិ ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដូចជាការសំលាប់មនុស្ស ។ល។ ក្នុងអាណត្តិដែលខ្លួនមានអំណាច ប្រជាពលរដ្ឋត្រូវប្រើសិទ្ធិអំណាចខ្លួន អំពាវនាវ ប្ដឹងទៅសភា ព្រឹទ្ធសភា តុលាការឯករាជ្យ ឬប្រើប្រាស់សិទ្ធិបញ្ចេញមតិ និង មហាបាតុកម្មដោយសន្តិវិធី ដើម្បីឱ្យដកអភ័យឯកសិទ្ធ និងចោទប្រកាន់ដាក់ទោស ទណ្ឌកម្ម ។

## ២១. តើលោក អ្នកត្រូវដោះស្រាយយ៉ាងណា នៅពេលជួប ឬប្រឈមមុខ ជាមួយនឹងឧបាយកលទុច្ចរិតក្នុងដំណើរការបោះឆ្នោត?

ឧបាយកលទុច្ចរិតមានដូចជា : ការគំរាមកំហែង ការបំភិតបំភ័យ ការទិញសន្លឹកឆ្នោត(ដោយសម្ភារៈ ឬប្រាក់កាស) ការលួងលោមទិញទឹកចិត្ត ការបង្ខំឱ្យធ្វើសម្បថ ការកត់លេខឯកសារបញ្ជាក់អត្តសញ្ញាណ ។ល។ និង ។ល។

ប្រជាពលរដ្ឋត្រូវរាយការណ៍ជាសម្ងាត់ដល់អ្នកសង្កេតការណ៍ ឬ ភ្នាក់ងាររបស់គណបក្សនយោបាយ ដែលលោកអ្នកទុកចិត្ត។ ប៉ុន្តែ បើលោកអ្នកជួបបញ្ហាចំពោះមុខគេកំពុងគំរាមកំហែង លោក អ្នកត្រូវដោះស្រាយដោយភាពទន់ភ្លន់ ដូចជា ÷

- បើលោក អ្នកនិយាយទៅដោយគ្មានផលវិបាក ឬគ្រោះថ្នាក់ដល់ខ្លួនទេនោះ លោក អ្នកអាចនិយាយថា " ***ក្នុងពេលនេះខ្ញុំពុំទាន់ធ្វើការសំរេចចិត្តនៅឡើយទេ សូមអភ័យទោស*** " ។
- បើចៀសមិនរួច លោក អ្នកត្រូវតែទទួលយក គួរប្រើពាក្យយ៉ាងទន់ភ្លន់ថា "

***ខ្ញុំនឹងបោះឆ្នោតឱ្យលោក ឬគណបក្សរបស់ លោក*** ”។

**ប៉ុន្តែ** ប្រការដែលត្រូវចងចាំនោះគឺ ការបោះឆ្នោតជា **ការសម្ងាត់** គ្មានអ្នកណាដឹងថាលោក អ្នកបោះឆ្នោតឱ្យគណបក្សណាមួយទេ។ ដូចនេះ លោក អ្នកត្រូវបោះឆ្នោត **តាមឆន្ទៈ និងការពេញចិត្ត**របស់ខ្លួន។

## ២២_ តើអ្វីខ្លះជាភាពឈ្លាសវៃរបស់អ្នកបោះឆ្នោត?

- អ្នកបោះឆ្នោត ត្រូវ/ចេះស្វះស្វែង ព្យាយាមតាមដានដោយយកចិត្តទុកដាក់រាល់ការអប់រំ ផ្សព្វផ្សាយ ផ្តល់ព័ត៌មានអំពីការបោះឆ្នោតរបស់ស្ថាប័នរៀបចំការបោះឆ្នោត សមាគម-អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងចេះអប់រំ ផ្សព្វផ្សាយបន្តដល់បងប្អូនប្រជាពលរដ្ឋជិតខាង និងមិត្តភ័ក្តិរបស់ខ្លួន ។
- អ្នកបោះឆ្នោតចេះដោះស្រាយនូវបញ្ហានានា (ឧបាយកលទុច្ចរិត) ពេលដែលខ្លួនជួប ឬប្រឈមមុខក្នុងអំឡុងពេលបោះឆ្នោតដោយសន្តិវិធី ដោយភាពវៃឆ្លាត ដើម្បីសុវត្ថិភាព។
- ពិនិត្យមើលបុគ្គលិកលក្ខណៈរបស់បេក្ខជន បេក្ខនារីឈរឈ្មោះ និងគោលនយោបាយ/កម្មវិធីនយោបាយរបស់គណបក្សនយោបាយនីមួយៗ។
- បោះឆ្នោតតាម**ឆន្ទៈ**របស់ខ្លួន ទោះបីគេគំរាមកំហែង យកសំភារៈ ឬលុយទិញទឹកចិត្ត បង្ខំឱ្យធ្វើសម្បថ ឬប្រើសកម្មភាពបង្ខិតបង្ខំយ៉ាងណាក៏ដោយ ដោយលោកអ្នកត្រូវយល់ពីគោលការណ៍នៃការបោះឆ្នោត “ **បោះឆ្នោតដោយសំងាត់ តាមឆន្ទៈ ដោយសេរី និងស្មើភាព** ” ។




# ផ្នែកទី៣

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ សិទ្ធិ និងនីតិវិធី

### ២៣. តើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់គឺជាអ្វី ?

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាដំណើរការជ្រើសរើសសភាឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ពី៥-១១នាក់ ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្រ ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមរយៈការបោះឆ្នោតជាសកល មានអាណត្តិ៥ឆ្នាំ ដោយសេរី ស្មើភាព ចំពោះ សម្ងាត់ ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមនីតិវិធីដូចមានចែងក្នុងច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ២៤. តើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់មានសារៈសំខាន់យ៉ាងណាខ្លះ ?

- មានប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន

- មានប្រពន្ធ័គ្រប់គ្រងបែបវិមជ្ឈការនៅតាមឃុំ សង្កាត់ ឬការផ្ទេរអំណាចនយោបាយ និងសេដ្ឋកិច្ចដល់ឃុំ សង្កាត់។

- ប្រជាពលរដ្ឋអាចសំរេចជោគវាសនាដោយខ្លួនឯង តាមរយៈតំណាងរបស់គាត់នៅថ្នាក់មូលដ្ឋាន។

- ប្រជាពលរដ្ឋនឹងទទួលបានការអភិវឌ្ឍជាក់ស្តែង

- ពង្រឹងស្ថានភាពនយោបាយ ដោយទទួលបានការទុកចិត្តពីប្រជាពលរដ្ឋ ។

## ២៥. តើនឹងមានអ្វីកើតឡើង នៅពេលលោក អ្នកមិនបានទៅបោះឆ្នោត?

**លោក អ្នកត្រូវតែទៅបោះឆ្នោត!** ការបោះឆ្នោតមានសារៈសំខាន់ណាស់ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីជ្រើសរើសអ្នកដឹកនាំតាមការពេញចិត្តរបស់ប្រជាពលរដ្ឋដែលជាអ្នកបោះឆ្នោត។ បើលោកអ្នកមិនទៅបោះឆ្នោតទេ មានន័យថា អ្នកដទៃជាអ្នកសំរេចចិត្តក្នុងការជ្រើសរើសអ្នកដឹកនាំជំនួសលោកអ្នក ហើយក៏មានន័យថា លោកអ្នកបានបោះបង់សិទ្ធិជាពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។ ម្យ៉ាងទៀត មានន័យថា លោកអ្នកបណ្តោយឱ្យអ្នកជាប់ឆ្នោតធ្វើអ្វីតាមតែអំពើចិត្ត មិនបំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយប្រទេសជាតិគ្មានការរីកចំរើន។

ដូចនេះ លោកអ្នកត្រូវតែទៅបោះឆ្នោតជ្រើសរើស អ្នកដឹកនាំឱ្យបានត្រឹមត្រូវ ដើម្បីអភិវឌ្ឍប្រទេសជាតិ ព្រោះវាជាសិទ្ធិ និងករណីយកិច្ចរបស់លោកអ្នក និងជាឱកាស

ដ៏ល្អរបស់លោកអ្នកក្នុងការជ្រើសរើសអ្នកដឹកនាំដែលខ្លួនពេញចិត្ត ។

កំលាំងចូលរួមរបស់លោកអ្នកក្នុងការបោះឆ្នោត និងជាមួយតំណាងដែលជាប់ឆ្នោត ប្រៀបដូចជាតំណក់ទឹកបំបែកផ្ទាំងសិលាមួយដ៏ធំ និងជាកំលាំងចលករជំរុញឱ្យមានការដោះស្រាយបញ្ហាទាំងឡាយក្នុងសង្គមមួយថ្ងៃបន្តិចៗ ដើម្បីពួកយើង កូនចៅជំនាន់ក្រោយ និងប្រទេសជាតិមានប្រជាធិបតេយ្យរឹងមាំ ។

## ២៦. តើលោក អ្នកត្រូវតែចូលជាសមាជិករបស់គណបក្សនយោបាយណាមួយឬទេដើម្បីបានទៅបោះឆ្នោត ?

**<u>មិនចាំបាច់ទេ</u>** ! ការបោះឆ្នោតគឺជាសិទ្ធិនយោបាយ និងជាសេរីភាពរបស់លោកអ្នក។ ដូចនេះ លោក អ្នក<u>មិនចាំបាច់</u>ចូលជាសមាជិកគណបក្សនយោបាយណាមួយឡើយ។ ទោះបីលោក អ្នកមិនមែនជាសមាជិកគណបក្សនយោបាយណាមួយក៏ដោយក៏លោក អ្នកមានសិទ្ធិបោះឆ្នោតដោយសេរីបានដែរ ។

## ២៧. តើអ្វីខ្លះជាផលវិបាកនៃការទិញ លក់សន្លឹកឆ្នោត?

ប្រសិនបើលោក អ្នកបោះឆ្នោតដោយការទិញ លក់សន្លឹកឆ្នោតនោះវាធ្វើឱ្យ ÷

- លោក អ្នក ក្លាយជាទាសករនៃអំណាច
- លោក អ្នកត្រូវគិតថា ជំនួយតែងមានចំណង ដូចពាក្យចាស់លោកពោលថា ***"ហុចរបស់ស្រណោះដៃ"*** ។
- បើលោក អ្នកបោះឆ្នោតតាមការ**ទិញ**សន្លឹកឆ្នោត យើងនឹងបានអ្នកជាប់ឆ្នោតជាតំណាងមិនល្អ ប្រើប្រាស់អំណាចហួសហេតុ ប្រព្រឹត្តអំពើពុករលួយដើម្បីបានប្រាក់យកមកទិញសន្លឹកឆ្នោតនៅពេលបោះឆ្នោតលើកក្រោយទៀតហើយកាន់អំណាចជារៀងរហូត

- បើយើង**លក់**សន្លឹកឆ្នោត យើងនៅតែក្រីក្រ គ្មានការអភិវឌ្ឍនៅមណ្ឌល ឬប្រទេសជាតិរបស់យើង អ្នកកាន់អំណាចមិនបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រកបរបររកស៊ី និងការងារ ។




សង្គមមានការរំលោភច្បាប់បោះឆ្នោត មិនគោរពសិទ្ធិមនុស្ស គ្មានប្រជាធិបតេយ្យ គ្មានយុត្តិធម៌ មានអំពើពុករលួយ គ្មានការអភិវឌ្ឍ និងបន្តភាពក្រីក្រ។

## ២៨. តើមានបញ្ហាអ្វីខ្លះអាចកើតឡើងក្នុងដំណើរការបោះឆ្នោត ?

- មានការទិញទឹកចិត្តតាមរយៈ សំភារៈ និង លុយកាក់ (ពិសេស ការទិញសន្លឹកឆ្នោតនៅយប់មុនថ្ងៃបោះឆ្នោតមួយថ្ងៃ) ។
- មានការបង្ខិតបង្ខំឱ្យប្រជាពលរដ្ឋធ្វើសម្បថ និងកត់លេខឯកសារបញ្ជាក់អត្តសញ្ញាណ
- មានការគំរាមកំហែង បំភិតបំភ័យ បង្ខិតបង្ខំលើប្រជាពលរដ្ឋ និងបេក្ខជន ឬសកម្មជនរបស់គណបក្សនយោបាយ ។
- ការរារាំង គំរាមកំហែងបេក្ខជនមិនឱ្យឈរឈ្មោះបោះឆ្នោត
- បង្កការលំបាក ឧបសគ្គដល់គណបក្សប្រឆាំង ឬគណបក្សតូចៗក្នុងការចុះបញ្ជីបេក្ខជន

- អ្នកមានសិទ្ធិបោះឆ្នោតត្រូវបានបដិសេធមិនឱ្យចុះឈ្មោះបោះឆ្នោត
- ចុះឈ្មោះឱ្យអ្នកដែលគ្មានសិទ្ធិបោះឆ្នោត
- បាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ (នៅថ្ងៃបោះឆ្នោត)
- ក្នុងពេលយុទ្ធនាការឃោសនា មិនគោរពគោលការណ៍ស្មើភាព (ឃោសនាមុនកាលកំណត់...) ។
- មានអំពើហិង្សា និងការសំលាប់ខាងនយោបាយ
- មិនធានានូវសុវត្ថិភាព សន្តិសុខ
- មិនធានានូវសេរីភាពក្នុងការបញ្ចេញមតិ
- អ្នកបោះឆ្នោតត្រូវបានបញ្ចុះបញ្ចូល ដើម្បីរារាំងមិនឱ្យទៅបោះឆ្នោត
- មានភាពយឺតយ៉ាវក្នុងដឹកជញ្ជូន និងផ្តល់សម្ភារៈបោះឆ្នោត
- មានភាពមិនប្រក្រតីក្នុងការដឹកជញ្ជូនហិបឆ្នោត
- មានភាពយឺតយ៉ាវក្នុងការរាប់សន្លឹកឆ្នោត
- ពេលរាប់សន្លឹកឆ្នោតមានការបន្លំ មានការរំខាន
- មានការរារាំងអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយមិនឱ្យចូលរួមសង្កេតការណ៍ ។
- អនុញ្ញាតិឱ្យអ្នកបោះឆ្នោតប្រើប្រាស់បណ្ណ័ព័តិមានអ្នកបោះឆ្នោតជំនួសឯកសារបញ្ជាក់អត្តសញ្ញាណនៅថ្ងៃបោះឆ្នោត ។
- មានការយល់ច្រឡំជាមួយប័ណ្ណព័តិមានអ្នកបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បោះឆ្នោត ដែលធ្វើឱ្យអ្នកបោះឆ្នោតត្រូវបានគេបដិសេធ ឬត្រូវបាន

ដេញឱ្យទៅយកឯកសារបញ្ជាក់អត្តសញ្ញាណ នាំឱ្យអ្នកបោះឆ្នោតមានការធុញទ្រាន់លែងមកបោះឆ្នោត ។

## យុទ្ធនាការឃោសនាបោះឆ្នោត

### ២៩_ តើការឃោសនាបោះឆ្នោតមានបំណងអ្វី?

ការឃោសនាបោះឆ្នោតមានបំណងឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ-សង្កាត់ ដល់អ្នកបោះឆ្នោត ។



### ៣០_ តើយុទ្ធនាការឃោសនាបោះឆ្នោតចាប់ផ្តើមនៅពេលណា និងបញ្ចប់នៅពេលណា?

- យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល **១៤ថ្ងៃ** គឺ ចាប់ពីថ្ងៃទី**២០ខែឧសភា** ដល់ថ្ងៃទី**០២** ខែមិថុនា ឆ្នាំ២០១៧ ហើយគ្រប់សកម្មភាពនៃការ ឃោសនាគឺត្រូវចបបញ្ឈប់ ២៤(ម្ភៃបួន)ម៉ោង **(២៤)ម៉ោងមុន**ថ្ងៃបោះឆ្នោត (១ថ្ងៃមុនថ្ងៃបោះឆ្នោត ហៅថា ***"ថ្ងៃស"***)។
- គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោងប្រាំមួយ(៦)ព្រឹក ដល់ម៉ោង ដប់ (១០)យប់ និងត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ដប់ (១០)យប់ ដល់ម៉ោង ប្រាំមួយ (៦)ព្រឹក។
- សកម្មភាពឃោសនាដោយឧបករណ៍បំពងសម្លេង ត្រូវហាមឃាត់ចាប់ពីម៉ោងដប់ពីរ (១២) ថ្ងៃត្រង់ ដល់ម៉ោងពីរ (២) រសៀល។

### ៣១_ តើសកម្មភាពអ្វីខ្លះដែលធ្វើឡើងក្នុងពេលឃោសនាបោះឆ្នោត ?

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើងជាសាធារណៈដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោ-បាយណាមួយ។

សកម្មភាពឃោសនារួមមាន÷

- ការជួបជុំជាសាធារណៈ របស់គណបក្សនយោបាយ ឬបេក្ខជន
- ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅឃុំ សង្កាត់យ៉ាងច្រើន ០២(ពីរ)ដង

ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

- ការជួបជុំ ឬឃោសនាតាមផ្ទះ ។
- ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។
- ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌីក្នុងរោងវីដេអូសាធារណៈ ឬទីសាធារណៈ ។
- សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា ។
- សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ។
- សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជនជូនអ្នកបោះឆ្នោត ។
- សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទប្រដាសផ្សាយ ។
- ការប្រគុំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ។
- ការរៀបចំកម្មវិធីប្រកួតកីឡា ។

## ៣២_ តើមធ្យោបាយដឹកជញ្ជូនណាខ្លះត្រូវបានហាមឃាត់នៅពេលឃោសនាបោះឆ្នោត?

មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរដ្ឋដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ស្លាកសញ្ញារាជការ រដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល។

## ៣៣_ តើនរណាខ្លះអាចចូលរួម និងនរណាខ្លះមិនអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះបេក្ខជន ឬគណបក្សនយោបាយណាមួយ?

- ***អ្នកមានសិទ្ធិចូលរួមគាំទ្រក្នុងសកម្មភាពឃោសនាគ្រប់ម៉ោង:*** គឺប្រជាពលរដ្ឋខ្មែរទាំងពីរ (០២) ភេទ។
- ***អ្នកមិនមានសិទ្ធិចូលរួមសកម្មក្នុងការឃោសនាក្នុងអំឡុងម៉ោងធ្វើការ:*** គឺមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ។ ប៉ុន្តែបន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ អ្នកទាំងនេះអាចចូលរួមក្នុងសកម្មភាពឃោសនាបោះឆ្នោតគាំទ្រចំពោះបេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឲ្យមានការគំរាមកំហែងឡើយ ។

## ៣៤_ មុននឹងបោះឆ្នោត តើលោក អ្នកត្រូវពិនិត្យមើលបេក្ខជន បេក្ខនារីឈរឈ្មោះដូចម្តេចខ្លះ?

- ដំបូងត្រូវពិនិត្យមើលបេក្ខជន-បេក្ខនារីឈរឈ្មោះក្នុងបញ្ជីគណបក្ស ថាតើមាន

ដាក់បេក្ខជន-បេក្ខនារីឆ្លាស់គ្នានៅលេខរៀងខាងលើឬទេ?(អ្នកនៅលេខរៀងខាងលើអាចមានលទ្ធភាពជាប់ឆ្នោតច្រើន) ហើយមានលក្ខណៈសម្បត្តិយ៉ាងណាខ្លះ?

※ បន្ទាប់មកបេក្ខជន-បេក្ខនារីនោះធ្លាប់ឈរឈ្មោះឬទេនៅអាណត្តិមុនៗ

※ បើគាត់ធ្លាប់ឈរឈ្មោះ តើបានជាប់ឆ្នោតឬទេ? ជាប់ឆ្នោតជាអ្វី(ជាក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងរាស្ត្រ)?

※ នៅពេលគាត់ជាប់ឆ្នោតក្នុងតំណែង តើគាត់យកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋ ក៏រិតណា? ហើយគួរបោះឆ្នោតឱ្យគាត់បន្តទៀតឬមួយយ៉ាងណា?

※ បើគាត់មិនធ្លាប់ឈរឈ្មោះ តើគាត់ធ្លាប់ធ្វើការជាអ្វី (មន្ត្រីរាជការ គ្រូបង្រៀន ពេទ្យ អាចារ្យ អ្នករកស៊ី)?

※ ពេលពួកគាត់នៅធ្វើការ តើពួកគាត់ធ្វើការល្អឬទេ? យកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋឬទេ?

※ បន្ទាប់មក ត្រូវពិនិត្យថា បេក្ខជន-បេក្ខនារីធ្លាប់រកស៊ីខុសច្បាប់ បន្លំ ឆបោក ទារប្រាក់ពីប្រជាពលរដ្ឋ ឬប្រព្រឹត្តិអំពើហឹង្សាក្នុងគ្រួសារ ឬឈ្លោះទាស់ទែងជាមួយអ្នកជិតខាងដោយមិនសមរម្យ រំលោភយកដីប្រជាពលរដ្ឋ ឬមានបញ្ហាផ្សេងៗទៀត។

※ តើគាត់មានគំនិតទូលំទូលាយ យល់ដឹងអំពីប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស គំនិតអធ្យាស្រ័យ ដោះស្រាយបញ្ហាដែរឬទេ?

※ តើគាត់មានការប្តេជ្ញាចិត្តក្នុងការលើកយកបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋដាក់ជូនរដ្ឋាភិបាលឬទេ?




※ តើគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំប្រទេសជាតិឱ្យរីកចំរើនបានឬទេ?

## ៣៥_ តើអ្នកបោះឆ្នោត ត្រូវស្វែងយល់អំពីកម្មវិធីនយោបាយរបស់គណបក្សឬទេ ?

**ត្រូវតែស្វែងយល់** ! ព្រោះបេក្ខជន/បេក្ខនារីគឺជាសមាជិកគណបក្សនយោបាយ!

- ត្រូវពិនិត្យមើលគោលជំហរ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ថាតើមាននិន្នាការទៅរកប្រជាធិបតេយ្យ ការអភិវឌ្ឍសេដ្ឋកិច្ច(ចង់ឱ្យប្រជាពលរដ្ឋមានជីវភាពធូរធារឬទុកឱ្យប្រជាពលរដ្ឋនៅក្រីក្រ) ការគោរពសិទ្ធិមនុស្ស ការនិយមលទ្ធិផ្តាច់ការ ការប្រើប្រាស់អំណាចហួសហេតុ(ការតែងតាំង ការដកបុគ្គលិក) ការប្រព្រឹត្តិអំពើពុករលួយ និងថាតើមានលើកយកវិធានការដោះស្រាយបញ្ហាស្ត្រី និងកុមារដែរឬទេ?
- ការទទួលខុសត្រូវរបស់គណបក្សនយោបាយ ការអនុវត្តតាមការសន្យា
- ការរៀបចំរចនាសម្ព័ន្ធក្នុងគណបក្សមានលក្ខណៈប្រជាធិបតេយ្យ មានការផ្លាស់ប្តូរ

ប្រធានគណបក្សឬទេ? មានការបោះឆ្នោតផ្ទៃក្នុងគណបក្សឬទេ? និងមានគោល-នយោបាយយេនឌ័រលើកកំពស់សិទ្ធិនារីឬទេ?

- តើអ្នកដឹកនាំគណបក្សនោះជានរណា?

## ៣៦‿ តើលោក អ្នកត្រូវមានសកម្មភាពអ្វីខ្លះក្នុងពេលឃោសនាបោះឆ្នោត?

- ចូលរួមស្តាប់ការឃោសនារបស់បេក្ខជនតាមរយៈ ការប្រជុំ មីទ្ទិញ ការផ្សាយតាមវិទ្យុ និងទូរទស្សន៍។
- មើល អានឯកសារឃោសនារបស់គណបក្ស ដូចជា ខិត្តប័ណ្ណ ផ្ទាំងរូបភាព ទូរទស្សន៍ និងឯកសារផ្សេងៗ។
- លើកឡើងពីតំរូវការចាំបាច់ក្នុងឃុំ សង្កាត់របស់ខ្លួនទៅបេក្ខជន( ស្ត្រី-បុរស) និងគណបក្សនយោបាយនីមួយៗ។
- សួរដេញដោលទៅបេក្ខជន និងគណបក្សនយោបាយនីមួយៗអំពីយុទ្ធសាស្ត្រធ្វើការងារតាមការសន្យាដោយជោគជ័យ ថាតើយុទ្ធសាស្ត្រទាំងនោះមានលក្ខណៈប្រាកដនិយម ឬច្បាស់លាស់អាចធ្វើបានដែរឬទេ? ឬគ្រាន់តែនិយាយក្នុងគោលបំណងទាក់ទាញសន្លឹកឆ្នោតពីអ្នកបោះឆ្នោតតែប៉ុណ្ណោះ? តើមានបានលើកឡើងអំពីការដោះស្រាយបញ្ហារបស់ស្ត្រីដែរឬទេ? តើមានគោលនយោបាយលើកស្ទួយស្ត្រីឱ្យក្លាយជាអ្នកដឹកនាំ សម្រេចចិត្តបានកំរិតណា?
- ស្រាវជ្រាវ និងពិភាក្សារកព័ត៌មានបន្ថែមពី បេក្ខជន គណបក្សនយោបាយ អ្នកជិតខាង និងបងប្អូនក្នុងភូមិឃុំ។

# នៅថ្ងៃបោះឆ្នោត

## ថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧




## ៣៧_ តើថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ_សង្កាត់អាណត្តិទី៤ ធ្វើឡើងនៅថ្ងៃ ខែ ឆ្នាំណា?

ថ្ងៃបោះឆ្នោតត្រូវធ្វើឡើងតែ**មួយថ្ងៃគត់** គឺ ***ថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧ ចាប់ពីម៉ោង ៧.០០ព្រឹក រហូតដល់ ម៉ោង ៣.០០រសៀល*** ។

## ៣៨_ ទីកន្លែងបោះឆ្នោត

អ្នកបោះឆ្នោត ត្រូវទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលឈ្មោះរបស់ខ្លួនមាននៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យនោះ (ទៅបោះឆ្នោតតាមលេខកូដការិយា-

ល័យ និងលេខរៀងឈ្មោះរបស់ខ្លួនដែលបានកត់ត្រាទុក)។

### ៣៩_ ដើម្បីបោះឆ្នោតបាន និងងាយស្រួល តើលោកអ្នកត្រូវធ្វើដូចម្តេច?

- ត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ
- ត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន (ឈ្មោះ សញ្ជាតិ អាយុ)
- ទៅឱ្យទាន់ម៉ោងពី ម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៣:០០ រសៀល
- ស្គាល់លេខកូតការិយាល័យ ទីតាំងការិយាល័យបោះឆ្នោត និងលេខរៀងឈ្មោះរបស់ខ្លួន។
- មិនមានទឹកខ្មៅប្រឡាក់ម្រាមដៃ

### ៤០_ តើអ្នកបោះឆ្នោតត្រូវមានតួនាទី ភារកិច្ច ដូចម្តេចខ្លះក្នុងថ្ងៃបោះឆ្នោត?

- ត្រូវទៅបោះឆ្នោត
- ត្រូវបោះឆ្នោតតាមឆន្ទៈរបស់ខ្លួន ទោះបីបេក្ខជន ឬគណបក្សណាមួយបានឱ្យលុយ សម្ភារៈ ឱ្យធ្វើសម្បថ ឬបំភិតបំភ័យយ៉ាងណាក៏ដោយ។ ត្រូវចងចាំថាការបោះឆ្នោតធ្វើឡើងដោយសម្ងាត់ គ្មាននរណាអាចដឹងបានទេ!
- ជួយពិនិត្យ និងផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតីក្នុងថ្ងៃបោះឆ្នោតទៅស្ថាប័នរៀបចំការបោះឆ្នោត អ្នកសង្កេតការណ៍ជាតិដូចជាខុមហ្វ្រែល (COMFREL ) និងអន្តរជាតិ ព្រមទាំងអ្នកសង្កេតការណ៍/និងឬភ្នាក់ងារគណបក្សនយោបាយ ។

### ៤១_ តើនរណាជាអ្នកសង្កេតការណ៍បោះឆ្នោតប្រជាពលរដ្ឋ?

- អ្នកបោះឆ្នោត (ស្ត្រី-បុរស) ទាំងអស់
- អ្នកសង្កេតការណ៍ប្រជាពលរដ្ឋ ឬអ្នកសង្កេតការណ៍បោះឆ្នោតប្រជាពលរដ្ឋ (អ្នកបោះឆ្នោត) នៅពេលចេញទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោតត្រូវសង្កេត

លើដំណើរការនៃការិយាល័យបោះឆ្នោតរបស់ខ្លួន ថាតើមានភាពមិនប្រក្រតីអ្វីខ្លះដែលបានកើតឡើងនៅទីនោះ។

- នៅពេលឃើញនូវភាពមិនប្រក្រតីមួយចំនួនកើតឡើង **អ្នកសង្កេតការណ៍ប្រជាពលរដ្ឋ**ត្រូវទូរស័ព្ទរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) តាមរយៈទូរស័ព្ទ

## ៤២. តើអ្វីខ្លះអាចធានាការសម្ងាត់នៃសន្លឹកឆ្នោត?(បើលោក អ្នកមានការជឿជាក់សូមជួយផ្សព្វផ្សាយបន្ត)

- ប្រជាពលរដ្ឋមានសិទ្ធិបដិសេធមិនឆ្លើយចំពោះសំណួរដែលចង់ដឹងថា ខ្លួនបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាមួយ ដោយមានសិទ្ធិរក្សាការសម្ងាត់នេះជាដាច់ខាត។

- ច្បាប់បោះឆ្នោតក៏បានធានាភាពសម្ងាត់នៃសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតពីជនណាដែលជជីកចង់ដឹង ឬគំរាមកំហែងអ្នកបោះឆ្នោត ឬលួងលោមសួរចង់ដឹង ឬប្រើប្រាស់មធ្យោបាយដើម្បីដឹងថា អ្នកបោះឆ្នោតបានបោះឆ្នោតគាំទ្រគណបក្ស ឬបេក្ខជនណាមួយនោះ ត្រូវមានទោសតាមច្បាប់បោះឆ្នោត។

- អ្នកបោះឆ្នោតត្រូវមានការជឿជាក់ថា គ្មានជាដាច់ខាតនូវឧបករណ៍ទំនើបការថតរូបតាមកុំព្យូទ័រ ឬតាមផ្កាយរណប ឬ បច្ចេកទេសវិទ្យាសាស្ត្រណាដែលអាចមើលឃើញ អាចដឹងពីការសម្ងាត់នៃសន្លឹកឆ្នោតបានឡើយ។

- សន្លឹកឆ្នោតដែលត្រូវបានប្រើប្រាស់គឺមិនមានការផ្ទៀងផ្ទាត់គល់បញ្ជីជាមួយនឹងសន្លឹកឆ្នោតទេ។ សន្លឹកឆ្នោតមានលក្ខណៈ និងសណ្ឋានដូចគ្នាដោយគ្មានអ្វីជា

សញ្ញាសំគាល់ឡើយ ។

■ ប្រជាពលរដ្ឋគួរស្វែងយល់ពីការរក្សាការសម្ងាត់នៃសន្លឹកឆ្នោត ។ អ្នកបោះឆ្នោតគូសសន្លឹកឆ្នោតនៅក្នុងបន្ទប់សម្ងាត់ហើយបត់សន្លឹកឆ្នោតដោយមិនមានអ្នកណាឃើញទេ ។ បន្ទាប់មកអ្នកបោះឆ្នោតទំលាក់សន្លឹកឆ្នោតទៅក្នុងហិបឆ្នោត នៅពេលនោះសន្លឹកឆ្នោតនឹងលាយឡំគ្នានៅក្នុងហិបឆ្នោតដោយគ្មានអ្នកណាដឹងថាសន្លឹកឆ្នោតណាមួយជារបស់អ្នកណាឡើយ ។

**ដូចនេះ** សូមលោក អ្នកជឿជាក់ថា ការបោះឆ្នោតជាការសម្ងាត់ គ្មានអ្នកណាដឹងថា លោក អ្នកសំរេចចិត្តបោះឆ្នោតឱ្យគណបក្សណា ឬ បេក្ខជនណាមួយឡើយ ។ លោកអ្នកនឹងរក្សាការសម្ងាត់របស់ខ្លួនបានជារៀងរហូត ។

### ៤៣_ តើលោកអ្នកត្រូវបោះឆ្នោតតាមការសន្យាចំពោះគណបក្សដែលបានផ្តល់ប្រាក់កាស សម្ភារៈ ឬដឹកជញ្ជូនលោកអ្នកមកកាន់ស្ថានីយ៍បោះឆ្នោត ឬគំរាមកំហែងលោកអ្នកតាមពាក្យសំដី ឬអាកប្បកិរិយាដែរឬទេ?

**មិនចាំបាច់បោះឆ្នោតឱ្យទេ** ! ការបោះឆ្នោត គឺជាការជ្រើសរើសដោយសេរីរបស់លោកអ្នក ដើម្បីគាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដែលលោកអ្នកពេញចិត្ត ។ គ្មាននរណាម្នាក់អាចបង្ខំលោកអ្នកឱ្យបោះឆ្នោតឱ្យគណបក្សណាមួយបានឡើយ ។

ទោះបីលោកអ្នកធ្លាប់សន្យាដោយស្ម័គ្រចិត្ត ឬដោយបង្ខំ( ស្បថស្បែ ) ជាមួយគណបក្សណាមួយ ឬបេក្ខជនណាមួយថានឹងបោះឆ្នោតឱ្យគេក៏ដោយ លោកអ្នកនៅតែមានសិទ្ធិសំរេចចិត្ត *ដោយសេរី តាមឆន្ទៈ និងការពេញចិត្តរបស់ខ្លួន* គឺមានតែលោកអ្នកម្នាក់គត់ដែលឈរក្នុងបន្ទប់សំងាត់បោះឆ្នោត ហើយគ្មាននរណាម្នាក់ដឹងថា លោកអ្នកបោះឆ្នោតឱ្យគណបក្សណាមួយឡើយ ។ សូមចងចាំថា *ការបោះឆ្នោតជាការសម្ងាត់* !

**៤៤. តើលោក អ្នកនឹងមិនទៅបោះឆ្នោតមែនទេ នៅពេលដែលមិនឃើញមានអ្វីប្រែប្រួលជីវភាពក្រោយពេលបោះឆ្នោត ?**

**សូមកុំអស់សង្ឃឹម!** សូមប្រែក្លាយការអស់សង្ឃឹមទៅជាការចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត។ សូមលោក អ្នកជឿជាក់ថា គេអាចយកតំណក់ទឹកទៅបំបែកផ្ទាំងសិលាដ៏ធំមួយបាន ដូចនេះ ការទៅបោះឆ្នោតជ្រើសរើសតំណាងរបស់លោក អ្នកតាមការពេញចិត្តមានសារៈសំខាន់ណាស់ ដើម្បីជាកំលាំងចលករជំរុញឱ្យអ្នកជាប់ឆ្នោតទទួលខុសត្រូវ និងដោះស្រាយបញ្ហាទាំងឡាយក្នុងសង្គមជាបន្តបន្ទាប់ ដើម្បីអនាគតពួកយើងកូនចៅជំនាន់ក្រោយ និងប្រទេសជាតិយើងឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងមានការរីកចំរើន។

**៤៥. បើលោក អ្នកជាជនពិការ (ដែលគ្មានលទ្ធភាពគូសសន្លឹកឆ្នោតដោយខ្លួនឯងបាន) តើលោក អ្នកអាចបោះឆ្នោតបានយ៉ាងដូចម្តេច?**

- **ពិតជាអាចបោះឆ្នោតបាន !** លោក អ្នក មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនដែលទុកចិត្តបំផុតទៅជាមួយ ឬមានសិទ្ធិសុំជំនួយពីប្រធានការិយាល័យបោះឆ្នោត។
- នៅពេលដែលប្រធានការិយាល័យបោះឆ្នោត បានចាត់តាំងមនុស្សម្នាក់ឱ្យជួយ ឬនីតិជនទៅជាមួយលោក អ្នក។ ជននោះនឹងនាំលោក អ្នកទៅបន្ទប់សម្ងាត់ ហើយសួរលោក អ្នកតិចៗថា តើលោកអ្នកចង់បោះឱ្យគណបក្សណាមួយ? អ្នកជំនួយការនោះនឹងជួយលោក អ្នកគូសលើសន្លឹកឆ្នោតត្រង់ឈ្មោះគណបក្សនយោបាយដែលលោក អ្នកមានបំណងបោះឱ្យនោះ និងណែនាំលោក អ្នកឱ្យស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតផងដែរ។
- ជំរើសដ៏ល្អបំផុតសម្រាប់លោក អ្នកជាជនពិការក្នុងការជ្រើសរើសអ្នកជំនួយពេល

បោះឆ្នោត គឺគួរយកបងប្អូន មិត្តភក្តិ ឬអ្នកណាដែលលោក អ្នកទុកចិត្តបំផុត ។

### ៤៦_ ក្នុងករណីអ្នកបោះឆ្នោតពិការម្រាមចង្អុលដៃស្តាំ តើអ្នកបោះឆ្នោតត្រូវប្រើម្រាមដៃណាដើម្បីជ្រលក់ទឹកខ្មៅ?

ក្នុងករណីនេះអ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងតាមលំដាប់ដូចតទៅ ៖ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើ រាល់ការជ្រលក់ ឬលាបផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាការបាន ។

### ៤៧_ តើលោក អ្នកអាចបោះឆ្នោតច្រើនដងបានដែរឬទេ?

***អត់បានទេ!*** អ្នកបោះឆ្នោតទាំងអស់មានសិទ្ធិបោះឆ្នោតបានតែ *មួយដងគត់* ហើយបានតែ *មួយសន្លឹក*ដូចៗគ្នា ។ ជនទាំងឡាយដែលបានបោះឆ្នោតហើយ មន្ត្រីការិយាល័យបោះឆ្នោតនឹងជ្រលក់ចង្អុលដៃស្តាំលោក អ្នក (កន្លែងផ្សេងទៀតបើជាជនពិការ) ក្នុងទឹកខ្មៅលុបលាងមិនជ្រះ ។ ប្រសិនបើមានស្នាមទឹកខ្មៅនេះនៅលើម្រាមដៃលោក អ្នក ប្រធានការិយាល័យនឹងប្រាប់ទៅភ្នាក់ងារគណបក្ស ឬអ្នកសង្កេតការណ៍ដើម្បីចំណាំ ហើយនឹងសួរនាំលោក អ្នកឱ្យពន្យល់អំពីមូលហេតុដែលមានស្នាមទឹកថ្នាំប្រឡាក់លើម្រាមដៃលោក អ្នក ។ ប្រសិនបើការពន្យល់របស់លោក អ្នកមិនសមហេតុផលទេនោះ ប្រធានការិយាល័យនឹងសន្និដ្ឋានថា លោក អ្នកព្យាយាមបោះឆ្នោត២ដង ។ ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់លោក អ្នកនឹងត្រូវដកហូត ហើយបញ្ជូនទៅគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ដើម្បីតាមដានបន្តទៀត ។

**៤៨. បើក្នុងករណីមានធុរៈចាំបាច់ តើយើងអាចឱ្យអ្នកដទៃទៅបោះឆ្នោតជំនួសបានដែរឬទេ?**

***អត់បានទេ !*** លោក អ្នកមិនអាចឱ្យអ្នកដទៃក្រៅពីខ្លួនយើងទៅបោះឆ្នោតជំនួសបានឡើយ។ អ្នកបោះឆ្នោតម្នាក់មានសិទ្ធិបោះឆ្នោតតែមួយសន្លឹក និងតែមួយដងគត់ក្នុងមួយអាណត្តិ ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់។ លោក អ្នកចាំបាច់ណាស់ត្រូវឆ្លៀតពេលទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ព្រោះថាការបោះឆ្នោត គឺជាជោគវាសនារបស់ភូមិ ឃុំ មណ្ឌល លោក អ្នកទាំងមូល ហើយត្រូវបានគេធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តង។

**៤៩. ចំពោះស្ត្រីមេផ្ទះដែលធ្វើការមមាញឹកនៅក្នុងផ្ទះ ហេតុអ្វីត្រូវខ្វល់ខ្វាយអំពីការបោះឆ្នោតនោះ?**

**ត្រូវតែចូលរួមក្នុងការបោះឆ្នោត !** បងប្អូននារី និងស្ត្រីមេផ្ទះ គួរចាប់អារម្មណ៍ថាយើងក៏ជាសមាជិកម្នាក់ក្នុងសង្គមជាតិដែរ។ ដូច្នេះយើងត្រូវមានតួនាទីយ៉ាងសំខាន់ចូលរួមក្នុងការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ ដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែប្រសើរឡើង។ ដូចនេះ ទោះបីជាបងប្អូននារី និងស្ត្រីមេផ្ទះមានការមមាញឹកច្រើននឹងកិច្ចការផ្ទះយ៉ាងណាក៏ដោយ សូមបងប្អូនឆ្លៀតពេលទៅបោះឆ្នោតឱ្យបានទាន់ពេលវេលា ព្រោះការបោះឆ្នោតគឺមានរយៈពេលតែមួយថ្ងៃគត់ យើងមិនត្រូវឱ្យឱកាសដ៏ល្អនេះកន្លងហួសទេ ព្រោះសន្លឹកឆ្នោតរបស់លោកស្រី នាងកញ្ញា*១សន្លឹកមានតម្លៃណាស់*សំរាប់អនាគតពួក យើងកូនចៅជំនាន់ក្រោយ និងអនាគតប្រទេសជាតិ។

**៥០. បើលោក អ្នកជាជាងជួសជុលគ្រឿងម៉ាស៊ីនយន្តហោះ រថយន្ត ម៉ូតូ តើត្រូវលាងសំអាតម្រាមដៃរបស់ខ្លួនឬទេមុនពេលទៅបោះឆ្នោត?**

***ត្រូវតែលាងដៃ (ម្រាមដៃស្តាំ-ឆ្វេង)ឱ្យបានស្អាត!*** ដើម្បីងាយស្រួលបោះឆ្នោត និងចំណេញពេលវេលា។ ព្រោះថា បើម្រាមដៃលោក អ្នកមានប្រឡាក់ប្រេងម៉ាស៊ីនដែលមាន**ពណ៌ក្រម៉ៅស្រដៀងនឹងស្នាមទឹកខ្មៅ**សម្រាប់ឱ្យអ្នកបោះឆ្នោតជ្រលក់ចង្អុលដៃនោះ ប្រធានការិយាល័យបោះឆ្នោត មន្ត្រីផ្សេងៗទៀត ភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិនឹងចាប់ផ្តើមសង្ស័យមកលើលោក អ្នក ហើយប្រធានការិយាល័យបោះឆ្នោតនឹងសួរនាំលោក អ្នកឱ្យពន្យល់អំពីមូលហេតុដែលមានស្នាមថ្នាំខ្មៅប្រឡាក់លើម្រាមដៃលោក អ្នក។ បើការពន្យល់របស់លោក អ្នកសមហេតុផល ប្រធានការិយាល័យបោះឆ្នោតនឹងអនុញ្ញាតឱ្យលោក អ្នកបោះឆ្នោត ប៉ុន្តែបើមិនសមហេតុផលទេ លោក អ្នកនឹងមិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ។ ដូច្នេះ លោក អ្នកត្រូវតែលាងសំអាតម្រាមដៃឱ្យបានស្អាតនៅមុនពេលចេញទៅបោះឆ្នោត។

# ផ្នែកទី៤

## ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត

**៥១. ហេតុអ្វីបានជាស្ត្រីត្រូវចូលរួមក្នុងឆាកនយោបាយ និងជាអ្នកដឹកនាំនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ?**

- ដើម្បីឱ្យបញ្ហាស្ត្រី និងកុមារត្រូវបានយកចិត្តទុកដាក់ដោះស្រាយ
- ដើម្បីឱ្យស្ត្រីអាចអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ខ្លួនក្នុងដំណើរការអភិវឌ្ឍន៍សង្គមជាតិ
- ស្ត្រីគ្រប់រូបមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ

- ដើម្បីឱ្យស្ត្រីមានឱកាសចូលរួមក្នុងតួនាទីធ្វើសេចក្តីសំរេចចិត្ត
- ដើម្បីចូលរួមក្នុងដំណើរការវិមជ្ឈការ និងប្រជាធិបតេយ្យ
- ស្ត្រីគឺជាភ្នាក់ងារដែលធ្វើឱ្យមានការប្រែប្រួលនៅក្នុងសង្គម និងធ្វើឱ្យមានការផ្លាស់ប្តូរស្ថានភាពស្ត្រី ។
- កាលណាមានស្ត្រីចូលរួមកាន់តែច្រើននៅក្នុងវិស័យនយោបាយ ពេលនោះស្ត្រីខ្លួនឯងនឹងមានទឹកចិត្តចូលរួមកាន់តែខ្លាំង និងជាគំរូសម្រាប់ក្មេងស្រីជំនាន់ក្រោយ ។
- ដើម្បីលើកស្ទួយតំលៃស្ត្រី និងសមភាពយេនឌ័រ
- ដើម្បីបង្ហាញថាស្ត្រីក៏មានសមត្ថភាពដូចបុរសដែរ
- ដើម្បីកាត់បន្ថយទស្សនៈ ***"ស្ត្រីជាភេទទន់ខ្សោយ"***
- ដើម្បីការពារសិទ្ធិស្ត្រី និងអភិវឌ្ឍស្ត្រី ។
- ការពារផលប្រយោជន៍ស្ត្រីទាំងមូល
- ស្ត្រី និងបុរសមានសេចក្តីត្រូវការដោយឡែកៗពីគ្នា
- បើស្ត្រីមិនបានចូលរួម ស្ត្រីនៅតែមិនមានឱកាស ខ្វះបទពិសោធ និងមិនបានបង្កើនសមត្ថភាព ។
- ស្ត្រីត្រូវមានការយល់ដឹងពីនយោបាយ ដើម្បីអាចជួយតំរង់ទិសរួមគ្នា
- ស្ត្រីចូលរួមផ្តល់មតិ បំពេញភាពខ្វះចន្លោះ
- ដើម្បីកែទំរង់នយោបាយ និងរចនាសម្ព័ន្ធច្បាប់របស់ជាតិ ដោយសន្តិវិធី

## ៥២. តើឧបសគ្គអ្វីខ្លះដែលរារាំងស្ត្រីមិនឱ្យចូលរួមក្នុងវិស័យនយោបាយ?

- ខ្វះគោលនយោបាយសមធម៌ជាលាយលក្ខណ៍អក្សរក្នុងការលើកកម្ពស់ និងផ្តល់

ឱកាសដល់ស្ត្រីនៅក្នុងគណបក្សនយោបាយ និងច្បាប់បោះឆ្នោត ។

- ខ្វះយន្តការពិសេសដើម្បីគាំទ្រ និងផ្តល់ឱកាសដែលជាវិធានការសម្រាប់ស្ត្រីចូលរួមលើគ្រប់វិស័យស្របតាមអនុសញ្ញាអន្តរជាតិស៊ី-ដ (CEDAW) ។
- ដោយសារទំនៀមទម្លាប់អភិរក្សនិយម និងវប្បធម៌ដែលត្រូវបានគេសន្មត់ និងឱ្យតម្លៃស្ត្រីទាបជាងបុរសនៅគ្រប់វិស័យនៅក្នុងសង្គម ។
- ខ្វះការផ្តល់ឱកាស និងការគាំទ្រពីបុរស និងសង្គម
- ខ្វះការលើកទឹកចិត្តពីគ្រួសារ និងស្វាមី
- ឋានៈទាបក្នុងយន្តការធ្វើសេចក្តីសំរេចចិត្ត
- ការរើសអើងរវាងតួនាទីបុរស-ស្ត្រីក្នុងវិស័យការងារ
- ខ្វះចំណេះដឹង ជំនាញ និងបទពិសោធ
- ខ្វះជំនឿលើខ្លួនឯង
- ជីវភាពគ្រួសារ ភាពក្រីក្រ

### ៥៣. តើការផ្តល់អំណាចដល់ស្ត្រីមានន័យដូចម្តេច?

ការផ្តល់អំណាចឱ្យស្ត្រី គឺមានន័យថា ជាការបង្កើតឱកាសគ្រប់គ្រាន់លើជីវិតខ្លួនផ្ទាល់ វាមានន័យថា :

- អំណាចក្នុងការធ្វើសេចក្តីសំរេច
- អំណាចក្នុងការធ្វើឱ្យសំលេងមានប្រសិទ្ធភាព
- អំណាចក្នុងការបញ្ចូលគំនិតទៅក្នុងរបៀបវារៈ
- អំណាចក្នុងការចរចាស្ថានការណ៍ថ្មីៗ
- អំណាចផ្ទាល់ខ្លួនក្នុងការជំទាស់នឹងទំនៀមទម្លាប់ចាស់ៗ

## ៥៤. តើត្រូវមានវិធានការពិសេសអ្វីខ្លះដើម្បីបង្កើនចំនួនស្ត្រីជាតំណាងអ្នកជាប់ឆ្នោត?

- "**ប្រព័ន្ធឆ្លាស់**" ជាដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយដែលអាចលើកទឹកចិត្តឱ្យគ្រប់គណបក្សនយោបាយដាក់បេក្ខជនស្ត្រីក្នុងបញ្ជីបេក្ខជនរបស់គណបក្ស ។ ការលើកទឹកចិត្តដើម្បីបង្កើតប្រពន្ធ័ឆ្លាស់ក្នុងគណបក្សក៏អាចត្រូវបានបង្កើតក្នុងក្របខណ្ឌច្បាប់ដែរ គឺនិយាយដល់ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត **ស្តីពីការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** ។ វិសោធនកម្មច្បាប់នេះ កែលម្អបន្ថែមលក្ខណៈនៃការដាក់ពាក្យចុះឈ្មោះបញ្ជី បេក្ខជននៃគណបក្សនយោបាយដែលតម្រូវឱ្យមានប្រពន្ធ័ឆ្លាស់គ្នារវាង បេក្ខជនស្ត្រី-បុរសតាំងពីលេខរៀងខាងលើរហូតដល់ក្រោម ។

- ដើម្បី**បង្កើតបរិយាកាសល្អប្រសើរ**សំរាប់ស្ត្រី និង**ធានានូវសុវត្ថិភាព**សម្រាប់បេក្ខនារី រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងគ.ជ.បបន្តអនុវត្តន៍ឱ្យបានតឹងរ៉ឹងនូវវិធានការពិសេស និងអន្តរាគមន៏ក្នុងការបញ្ឈប់រាល់សកម្មភាពគំរាមកំហែងបំភិតបំភ័យនិងអំពើហឹង្សាលើអ្នកបោះឆ្នោតស្ត្រី បេក្ខនារី និងសកម្មជនស្ត្រីនយោបាយ ។

- បញ្ចប់រាល់ទម្រង់នៃការរើសអើងមកលើស្ត្រី ដោយឲ្យតម្លៃ និងផ្តល់ឱកាសឲ្យស្ត្រី ចូលរួមដោយស្មើភាពជាមួយបុរស តាមរយៈប្រើប្រាស់

យន្តការពិសេសដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រី ។

- **ប្រពន្ធ័ផ្សព្វផ្សាយ**ផ្តោតការ *អប់រំ* ដល់អ្នកបោះឆ្នោតអំពី សារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងពង្រឹងការទទួលបានការ *ផ្សព្វផ្សាយដោយស្មើភាព* របស់បេក្ខជនស្ត្រី ។
- **ប្រជាពលរដ្ឋកម្ពុជាដែលមានសិទ្ធិ**បោះឆ្នោតទាំងស្ត្រី និងបុរស សូមទៅបោះឆ្នោតកុំបីខាន ដោយសម្រេចចិត្ត *បោះឆ្នោតឱ្យគណបក្ស*ដែលមានបេក្ខភាពស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើពី ១ ដល់ ៣ ។

# ផ្នែកទី៥

## យុវជន និងនយោបាយ
## យុវជនចូលរួមក្នុងការបង្កើនចំនួនស្ត្រីនៅថ្នាក់សម្រេចចិត្ត

### ៥៥. តើមនុស្សប្រភេទណាដែលគេចាត់ទុកជាយុវជន-យុវនារី?

គឺជាក្រុមមនុស្សដែលមានវ័យក្មេងៗពោរពេញដោយថាមពល ទាំងកាយ និងបញ្ញា ។ ពួកគេជាក្រុមមនុស្សដែលងាយមានការផ្លាស់ប្តូរដែលការផ្លាស់ប្តូរទាំងនោះអាស្រ័យទៅតាមបរិស្ថានជុំវិញពួកគេ ។ ក៏ប៉ុន្តែក្រុមមនុស្សទាំងនេះ ត្រូវបានគេកំណត់អាយុខុសៗគ្នា ទៅតាមអង្គភាព ឬ តំបន់ ឬ ទៅតាមប្រទេស

ខុសៗគ្នាដូចជា[១] ÷

- ប្រទេសកម្ពុជា ក្រសួងអប់រំបានកំណត់យកយុវជនចាប់ពី១៥ឆ្នាំ ទៅ៣០ឆ្នាំ។ រីឯសមាគមយុវជនខ្មែរកំណត់ យក ពី១៦ឆ្នាំ ទៅ៣៥ឆ្នាំ។
- អង្គការសហប្រជាជាតិកំណត់យកពី ១៥ឆ្នាំ ទៅ២៤ឆ្នាំ
- ប្រទេសថៃ កំណត់ពី១៤ឆ្នាំ ទៅ២៥ឆ្នាំ
- ប្រទេសម៉ាឡេស៊ី កំណត់យកក្រុមមនុស្សអាយុក្រោម៤០ឆ្នាំ

### ៥៦_ តើយុវជនចាំបាច់ចូលរួមក្នុងកិច្ចការនយោបាយដែរឬទេ? ព្រោះហេតុអ្វី?

យុវជន (ប្រុស-ស្រី) ចាំបាច់ត្រូវតែចូលរួមក្នុងវិស័យនយោបាយ។ ព្រោះយុវជន ក៏ដូចជាក្រុមមនុស្ស ដទៃទៀតដែរ។

- មានតម្រូវការផ្ទាល់ខ្លួន
- ជាសរសរទ្រូងរបស់ជាតិ ជាកំលាំងស្នូល ជាក្រុមមានមនសិការខ្ពស់ កំលាំងកាយបរិបូរណ៍ និងមាន កម្លាំងស្មារតី និងឆន្ទៈមុតមាំ។
- មានគំនិតសុទិដ្ឋិនិយមច្រើន មានទឹកចិត្តស្នេហាជាតិខ្ពស់ និងមាន គំនិតច្នៃប្រឌិត ថ្មីៗខុសពីអ្នកជំនាន់មុនៗ ដែលមានគំនិតអភិរក្សនិយម

[១] តាមការបកស្រាយពីលោកយង់ គីមអេង ប្រធានមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងជាអតីតប្រធានសមាគមយុវជនខ្មែរ

ច្រើន ។

- តម្រូវការខុសពីអ្នកជំនាន់មុន ដោយសារពួកគេរស់នៅក្នុងសង្គមដែលពោរពេញ ដោយភាពប្រែប្រួល វិវត្តន៍លឿន ជាពិសេសនាពេលបច្ចុប្បន្ននេះ ។
- ធ្វើឱ្យមានការប្រែប្រួលក្នុងសង្គម នៅពេលដែលតម្រូវការរបស់ខ្លួនត្រូវបានគេមើលរំលង និងមិនបាន ដោះស្រាយ ។
- អាចជំរុញឱ្យយុវជនក្លាយជាអ្នកដឹកនាំផងដែរ ។

**៥៧_ តើយុវជនគួរធ្វើយ៉ាងណា ដើម្បីឱ្យមានការគិតគូខ្ពស់ពីអ្នកកាន់អំណាចលើបញ្ហារបស់យុវជន?**

- ដំបូងយុវជនត្រូវបង្ហាញថាខ្លួនគឺជាអ្នកដែលមានសក្តានុពលក្នុងការធ្វើឱ្យសម្លេងឆ្នោតមានការប្រែប្រួល ។
- យុវជនជាអ្នកបោះឆ្នោតដ៏គួរឱ្យចាប់អារម្មណ៍ពីគណបក្សនយោបាយ ។ តែអ្វីដែលសំខាន់នោះ គឺ យុវជនត្រូវធ្វើយ៉ាងណាឱ្យមាន**សម្លេងរួម ដើម្បីផលប្រយោជន៍រួម**របស់ពួកគេ ។
- យុវជនក៏ត្រូវបង្ហាញដល់ថ្នាក់ដឹកនាំដែរថា ខ្លួនមានឥទ្ធិពលទៅលើក្រុមមនុស្សដទៃទៀត ដូចជា មនុស្សជំទង់ ឬ មនុស្សចាស់ ព្រោះខ្លួនគឺជាយុវជនដែលមាន ចំណេះដឹង និងកំលាំងកាយរឹងមាំ ហើយអាចធ្វើការអប់រំ និងជួយដល់មនុស្សដទៃទៀត ។

## ៥៨_ តើយុវជនគួរធ្វើយ៉ាងណាដើម្បីឱ្យខ្លួនមានតំលៃក្នុងសង្គម?

- ទោះមានចំណេះដឹងជ្រៅជ្រះ ឬ តិចតួច ឬ មិនមានក្តី យុវជនត្រូវតែធ្វើ **អត្តចរិត ឱ្យបានសមជាពលរដ្ឋល្អ**
- យុវជន ត្រូវតែព្យាយាមធ្វើការ**តាមដាន**រាល់ការដឹកនាំរបស់អ្នកនយោបាយ អ្នកដឹកនាំ ហើយត្រូវចេះ**លើកយកបញ្ហា** ដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍប្រទេស ជាតិមកធ្វើការជជែកពិភាក្សា ជាមួយក្រុម ឬ អង្គការសមាគមយុវជនដទៃ ទៀត ឬ ជាមួយអ្នកនយោបាយតាមគ្រប់មធ្យោបាយដូចជា **ចូលរួម**ក្នុងវេទិកានានាដែល រៀបចំឡើងដោយអង្គការ សង្គមស៊ីវិល គណបក្សនយោបាយ និង រដ្ឋាភិបាលជាដើម ។
- យុវជនត្រូវតែ**ធ្វើជាមនុស្សគំរូ**ដល់អ្នកជំនាន់បន្ទាប់ៗ ក្នុងការចូលរួមកិច្ចអភិវឌ្ឍន៏សង្គម ការប្រឆាំងនឹងអំពើ ឧបាយមុខដូចជា ការជួញដូរមនុស្ស ការសេព គ្រឿងញៀន គ្រឿងស្រវឹង ល្បែងស៊ីសង និងចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ល។
- នៅពេល**គ្រប់អាយុ១៨ឆ្នាំ** យុវជនត្រូវតែព្យាយាមបំពេញកាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋ គឺត្រូវ**ទៅចុះឈ្មោះ** និង**ទៅបោះឆ្នោត**ជ្រើសរើសតំណាងរបស់ខ្លួនទៅ តាមឆន្ទៈ ដោយមានការពិចារណា និងថ្លឹងថ្លែងឱ្យបានហ្មត់ចត់ ។
- **ក្រោយពេលបោះឆ្នោត** យុវជនត្រូវតែខិតខំ**សង្កេតតាមដាន ឃ្លាំមើល**

សកម្មភាពអនុវត្តរបស់មន្ត្រីជាប់ឆ្នោត រាជរដ្ឋាភិបាល ដើម្បី ចូលរួមវាយតំលៃលើលទ្ធផល នៃសកម្មភាពទាំងនោះ ហើយផ្តល់ព័តិមានទាំងនេះទៅដល់ អ្នកបោះឆ្នោតដទៃទៀតសំរាប់ធ្វើជាទុនពិចារណាក្នុងការសំរេចចិត្តបោះឆ្នោតលើកក្រោយៗទៀត។

- ខិតខំ**បង្កើនចំណេះដឹង** និង**កសាងសមត្ថភាពផ្ទាល់ខ្លួន**បន្ថែមទៀត។

## ៥៩_ យុវជនត្រូវធ្វើសកម្មភាពអ្វីខ្លះក្នុងការចូលរួមបង្កើន ចំនួនស្ត្រីចូលរួមក្នុងកិច្ចការនយោបាយ និងជាប់ឆ្នោត ?

● ជម្រុញយុវតីដែលមានសក្តានុពល ឲ្យឈរឈ្មោះជាបេក្ខជន

● ជួយអប់រំ ផ្សព្វផ្សាយដល់យុវជន និងអ្នកបោះឆ្នោតអំពី «សារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ និងថ្នាក់សម្រេចចិត្ត (តាមរយៈវិទ្យុ វេទិកា កិច្ចប្រជុំ ប្រព័ន្ធផ្សព្វផ្សាយសង្គម ការជួបផ្ទាល់ ។ល។ និង។ល។)

● ចូលរួមក្នុងសកម្មភាពតស៊ូមតិជាមួយក្រុមការងារស្ត្រី និងព្រឹត្តិការណ៍នានារបស់សង្គមស៊ីវិល

● តាមដាន និងទៅមើលបញ្ជីបេក្ខជន បេក្ខនារីឈរឈ្មោះដែលមានបិទនៅតាមស្នាក់ការរបស់គ.ឃ/ស.ប និងកត់ត្រាទុក ថាតើគណបក្សណាខ្លះដែលដាក់ស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើ (លេខរៀងទី១ ឬ លេខរៀងពី១-៣ត្រៀមទុកសម្រាប់ថ្ងៃបោះឆ្នោត) ។




● ចូលរួម និងតាមដានការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយជាពិសេសក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ។

● បោះឆ្នោតឲ្យបេក្ខជនស្ត្រី (នៅថ្ងៃបោះឆ្នោត)

ខុមហ្វ្រែល COMFREL

# គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

# COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA


ទីស្នាក់ការកណ្តាល ផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ 1145,

ទូរស័ព្ទ: 023 884 150

ទូរសា: 023 883 750

#138, St. 122 , Teuk Laak I, Toul Kork, Phnom Penh, CAMBODIA

P.O. Box 1145

Tel: 023 884 150 / 012 942 019

Fax: 023 883 750

Email: comfrel@online.com.kh

Website: www.comfrel.org